ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១៥-១៦

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

# បញ្ជីរឿង

ទំព័រ


១ — វិទ្យុធម្មទេសនា កណ្ឌទី ៣ ព្រះគ្រូមុនីសុវេធ (ពេត-ប៉ិតសីលោ) ក្រុមជំនុំព្រះត្រៃបិដកសំដែង . . . . . . . . . . . . . . . . . . ១

២ — បិសាចស្នេហា យ. និពន្ធមន្ត្រី អ្នកតែងសេចក្ដីនៅព្រះរាជបណ្ណាល័យ ជាអ្នកតែង . . . . . . . . . . . . . . . . . . . . ៨

៣ — កុម្ភជាតក លោកគ្រូអាចារ្យ ឈឹម-ស៊ុម គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ប្រែនិងរៀបរៀង ពីគម្ពីរខុទ្ទកនិកាយ ព្រមទាំងអដ្ឋកថា . . . . . . . . . . ២៦

៤ — ពិធីទ្វាទសមាស តាមទំនៀមព្រាហ្មណ៍ នៅនគរពារាណសី (ប្រទេសឥណ្ឌា) តមកនិងចប់ . . . . . . . . . . . . . . . . . . . . ៣៥

៥ — លោកនេយ្យ ពាក្យកាព្យ របស់លោកអ្នកឧកញ៉ាវង្សាសព្វេជ្ញ (នង) (តមក) . . ៤០

៦ — ប្រវត្តិពួកឧបាសិកា ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់; ទី ២- ប្រវត្តិនាងវិសាខា-មិគារមាតា . . . . . . . . . . . . . . . . . . . . . . . ៤៩

៧ — រឿងព្រេងខ្មែរ រឿងអមាត្យរក្សាឃ្លាំព្រះរាជទ្រព្យ . . . . . . . . . . ៥៩

# TABLE DES MATIÈRES

Pages

1. Vidyudhammadesanā (Conférence faite à la Radio Phnom-Penh) par le vénérable Préas Kroû Munisuméth Thitasilo, membre de la Commission du Tripitaka................ 1

2. Bisach-Snéhā, roman par Kh. Nibandha-Mantri (1ère partie).. 8

3. Kumbhajātaka, traduit du pāli par le Vénérable Chhim-Soum professeur de l'Ecole supérieure de pāli (1ère partie)....... 26

4. Cérémonies brahmaniques des douze mois à Bénarès (Inde) par l'Okhnha Tep Pitou Krasem (suite et fin)............ 35

5. Lokaneyya, poème par feu l'Okhnā Vongsasarpejña (Nong) (suite)........................................ 40

6. La vie des disciples du Bouddha, II. La vie du Visākhā-Migāramatā........................................ 49

7. Conte populaire cambodgien inédit: " Le gardien de l'orange du Malabar d'un roi"............ ...................... 59

## វិទ្យុធម្មទេសនា កណ្ឌទី ៧

# អំពីទោសនៃសេចក្ដីល្ងង់

ព្រះគ្រូមុនីសុមេធ (ប៉ិតសីលោ) ក្រុមជំនុំព្រះត្រៃបិដក សំដែង

នៅថ្ងៃអង្គារ ១៤ រោចខែចេត្រ ឆ្នាំមមីចត្វាស័ក ព. ស. ២៤៨៥

(ត្រូវនឹង ១៤ អាវ្រិល ឆ្នាំ ១៩៤២)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

អវិជ្ជា បរមំ មលំ

សេចក្ដីល្ងង់ខ្លៅ ជាមន្ទិលដ៏ក្រៃលែង ។

អធិប្បាយថា ធម្មតាមនុស្សក្នុងលោកទាំងអស់ គ្មានអ្នកណាមួយត្រូវការប្រាថ្នាចង់បានរបស់ដែលជាមន្ទិលស្មោកគ្រោកទេ មានតែចំប្រាថ្នាស្វែងរករបស់ដែលបរិសុទ្ធស្អាតប្រពៃមកកំចាត់បង់របស់ដែលជាមន្ទិលប្រែះស្នឹមនោះជាដរាប ព្រោះថារបស់អាក្រក់ទាំងនោះសុទ្ធតែនាំបណ្ដាលឲ្យកើតទៅជាទោសទុក្ខ ដូចយ៉ាងមន្ទិលញើសក្អែលដែលជក់ជាប់នឹងសំពត់អាវ ឬរបស់ប្រើប្រាស់ផ្សេងៗ គេមិនត្រូវទុកផ្អាប់ឲ្យដុះស្នឹមយូរពេកទេ តែទុកយូរទៅនឹងធ្វើគ្រឿងប្រដាប់ទាំងនោះឲ្យជាំជាមពុកផុយរលួយឆាប់ ។

រាងកាយរបស់មនុស្សក៏គេត្រូវតែសំអាតជាដរាប គេមិនត្រូវបណ្ដោយឲ្យញើសក្អែលមកកកកុញរួបរឹតច្រើនពេកទេ ព្រោះខ្លាចរបស់គ្រោក់ទាំង

នោះនាំបណ្តាលឲ្យទៅជាទោសគឺកើតរោគព្យាធិផ្សេងៗ មានរោគកមរមាស់កើតអំពីស្បែកជាដើម ។

"អវិជ្ជា បរមំ មលំ"

សេចក្តីល្ងង់ខ្លៅ ជាមន្ទិលដ៏ក្រៃលែង ។ សេចក្តីមិនចេះមិនដឹង ហៅថាសេចក្តីល្ងង់ បើមិនចេះអក្សរនិងលេខ ហៅថាល្ងង់ក្នុងអក្សរនិងលេខ បើមិនចេះធ្វើការអ្វីហៅថាល្ងង់ក្នុងការងារនោះ បើមិនចេះគិតហៅថាល្ងង់ក្នុងការគិត ។ អ្នកណាមានសេចក្តីល្ងង់ អ្នកនោះហៅថាឥតចំណេះវិជ្ជា អ្នកណាឥតមានចំណេះវិជ្ជា អ្នកនោះហៅថាមនុស្សល្ងង់ៗ បើនឹងធ្វើការអ្វី ការនោះមិនកើត បើទុកជាកើតក៏មិនល្អ បើនឹងនិយាយពាក្យណាពាក្យនោះមិនប្រាកដ បើនឹងគិតហេតុអ្វីហេតុនោះមិនចេញមកសំដែងឲ្យប្រាកដជាខុសឬត្រូវបាន ។

មនុស្សល្ងង់មានឧបមាដូចមនុស្សខ្វាក់ ធម្មតាមនុស្សខ្វាក់កម្រនឹងដើរតាមផ្លូវឲ្យត្រង់និងរហ័សបាន នោះមានសេចក្តីញញើតញញើមរញ្ញកស្ទាក់ស្ទើរក្នុងចិត្តជានិច្ច ម៉្លោះហើយសេចក្តីមិនប្រាកដក្នុងចិត្តនោះ ក៏ធ្វើដំណើរមិនឲ្យប្រាកដ មិនដឹងជាទៅមុខឬថយក្រោយ តែងទើសទាស់ទទឹសទទាសមានទំនងដូចមនុស្សល្ងង់ខ្លៅ បើនឹងធ្វើ និយាយ ឬគិត ក៏ឥតមានប្រាកដក្នុងចិត្ត សេចក្តីមិនប្រាកដនេះឯង មិនអាចនឹងធ្វើប្រយោជន៍ដែលខ្លួនត្រូវការឲ្យសម្រេចទៅបានឡើយ ។

មានពុទ្ធភាសិតមួយកន្លែងសំដែងថា មោហៈគឺសេចក្ដីល្ងង់ខ្លៅ តែមានកន្លែងសន្ដានអ្នកឯណាហើយ មិនអាចធ្វើអ្នកនោះឲ្យស្គាល់សេចក្ដីអាក្រក់ល្អ និងខុសត្រូវបានឡើយ ។

មានសុភាសិតពីបុរាណកន្លែងហិតោបទេស ជាភាសាសំស្ក្រឹតសំដែងទុកថា "មានកូនដែលគ្មានចំណេះវិជ្ជា ជាមនុស្សខ្លៅ មិនប្រព្រឹត្តតាមគន្លងធម៌ និងមានប្រយោជន៍អ្វីដោយកូនដូច្នោះ ឧបមាដូចមនុស្សភ្នែកខ្វាក់ និងមានប្រយោជន៍អ្វីដោយភ្នែកខ្វាក់នោះ មានតែនាំឲ្យអផ្សុកព្រួយចិត្តតែម្យ៉ាង" ។

កូនមាន ៣ យ៉ាង គឺកូនដែលមិនទាន់កើត ១ កូនដែលកើតហើយស្លាប់បាត់ទៅវិញ ១ កូនដែលកើតហើយនៅរស់តែល្ងង់ខ្លៅ ១ ។ បណ្ដាកូនទាំង ៣ យ៉ាងនេះ គួរយកកូន២ខាងដើម ព្រោះថាបើមានទុក្ខព្រួយក៏មានតែ ១ គ្រាហើយបាត់ទៅវិញ ឯកូនមួយទី ៣ នោះមិនគួរយកទេ ព្រោះកូននោះនឹងនាំបណ្ដាលឲ្យបានសេចក្ដីទុក្ខព្រួយជានិច្ចជាកាល ។

អ្នកណាមួយ ទោះបីមានរូបឆោមលោមពណ៌ល្អ កំពុងតាំងនៅក្នុងតរុណវ័យ គឺនៅក្មេងកំឡោះក្រមុំនៅឡើយ កើតនៅក្នុងត្រកូលខ្ពង់ខ្ពស់ក្ដី តែប្រាសចាកចំណេះវិជ្ជា គឺឥតមានចេះដឹងអ្វីឡើយ អ្នកនោះឯងជាមនុស្សឥតពសី ឥតមានដំឡៃដូចគ្មានផ្កាបារ មានពណ៌ល្អស្រស់ តែឥតមានក្លិនក្រអូបបន្តិចឡើយ ។

មានសុភាសិតមួយបទទៀតថា "មនុស្សនិងសត្វមានអាការបរិភោគអាហារ រួមរសមេថុន និងដេកដូចគ្នា តែមនុស្សមានចំណេះវិជ្ជា សំរាប់ធ្វើឲ្យប្លែកអំពីសត្វ មនុស្សណាឥតមានចំណេះវិជ្ជា មនុស្សនោះស្មើគ្នានិងសត្វដូច្នេះ" ។

ដែលនាំរឿងសុភាសិតខ្លះមកអធិប្បាយក្នុងទីនេះដើម្បីឲ្យឃើញថា សេចក្ដីល្ងង់នេះតែអ្នកឯណាមិនខំស្វាហាប់ជំរះគោសរួសចេញទេ និងប្រែក្លាយទៅជាទោស ធ្វើអ្នកនោះឲ្យបានដល់នូវសេចក្ដីទន់ទាបថយថោកទាំងពីក្នុងបច្ចុប្បន្ននេះជាប់ដល់ទៅលោកខាងមុខដោយពិត ឯទោសសេចក្ដីល្ងង់និងឃើញប្រាកដក្នុងបច្ចុប្បន្ននេះដូច្នេះ:

១) បើល្ងង់ក្នុងវិធីអក្សរ គឺមិនចេះសរសេរ មិនចេះមើលនិងនាំឲ្យខាតបង់ប្រយោជន៍ដូច្នេះ:

ក. មិនអាចមើលសាស្ត្រា ឬសៀវភៅដែលមានច្បាប់ប្រដៅប្រយោជន៍ល្អក្នុងព្រះពុទ្ធសាសនា ឬក្រៅព្រះពុទ្ធសាសនាជាគ្រឿងនាំឲ្យកើតគំនិតប្រាជ្ញា ។

ខ. មិនអាចសរសេរសំបុត្រដោយខ្លួនឯង ឲ្យដំណឹងដល់ញាតិមិត្តជិតឆ្ងាយដែលខ្លួនត្រូវការឲ្យដំណឹង ។

គ. សេចក្ដីកំបាំងឬការក្រៃដែលញាតិមិត្តធ្វើសំបុត្រឲ្យដំណឹងមកចំពោះខ្លួននោះ និងមិនសំរេចប្រយោជន៍ ។

២) អ្នកដែលឥតមានចំណេះវិជ្ជាអ្វី បើនៅអាស្រ័យជ្រកកោនក្នុងសំណាក់អ្នកធំ ចេះគោរពប្រណិប័តន៍ឲ្យអ្នកធំលោកស្រឡាញ់អាណិតមេត្តាដូចម្ដេចក្តី អ្នកធំនោះក៏មិនអាចនឹងលើកដំកើងអ្នកល្ងង់ខ្លៅនោះឲ្យមានកេរ្តិ៍ឈ្មោះយសសក្តិបានឡើយ ព្រោះលោកយល់ថាខ្លួនល្ងង់ខ្លៅ បើគ្រាន់បើណាស់ក៏បានត្រឹមតែសេចក្តីសុខ ព្រោះអាស្រ័យនឹងឥស្សរ-ភាពរបស់អ្នកធំនោះប៉ុណ្ណោះ តែក៏គង់មិនរួចផុតអំពីដំណែងដែលជាអ្នកបំរើគេ ។

៣) មនុស្សល្ងង់ ទោះបីមានយសសក្តិ ដោយអំណាចព្រេងសំ-ណាងជួយឧបត្ថម្ភ បើថ្កុំថ្កើងគ្រាន់បើបានតែក្នុងទីឯទៀត តែដល់ក្នុងទីប្រជុំ ក៏នឹងត្រឡប់ទៅជាមនុស្សឥតកេរ៍ឥតដំឡៃទៅវិញ ព្រោះមិនចេះរៀបចំធ្វើការឫកពាឲ្យសមគួរដល់ឋានៈរបស់ខ្លួន ឬនឹងហានិយាយស្តីឡើងក៏មិនត្រូវទំនងធម៌នឹងទំនងច្បាប់ ជាហេតុឲ្យអ្នកឯទៀតគេពេបជ្រាយ ដោយអាការមើលងាយ ម៉្លោះហើយគេពុំជឿស្តាប់ ពុំកោតខ្លាច ដោយគេដឹងថាខ្លួនជាមនុស្សល្ងង់ ។

៤) មនុស្សល្ងង់ជាមនុស្សខ្សត់មិត្តសំឡាញ់ ព្រោះគេមិនសូវត្រូវការយកខ្លួនធ្វើជាមិត្តសំឡាញ់ ព្រោះគេដឹងថាខ្លួនជាមនុស្សល្ងង់ បើនឹងពឹងរកយកទៅឲ្យជួយធ្វើអ្វី ឬជួយពិគ្រោះប្រឹក្សាការអ្វីក៏មិនកើតទាំងអស់ ។

បើទុកជាមានមិត្តសំឡាញ់ ក៏ប្រែទៅតែបានមិត្តសំឡាញ់ដែលជាមនុស្សល្ងង់ដូចគ្នា ៗ

៥) មនុស្សល្ងង់ បើជាគេស៊ីតាមធម្មតាក៏មិនអាចនឹងធ្វើការឲ្យបានចំរើន ដូចអ្នកដែលមានប្រាជ្ញាចេះដឹងទេ ព្រោះខ្លួនមិនស្គាល់ទំនងនៃរបររកស៊ី មានមិនស្គាល់កាលដែលត្រូវធ្វើ នឹងមិនត្រូវធ្វើជាដើម ហើយទៅធ្វើឲ្យខុសទំនងខុសកាល ៗ កាលបើដូច្នេះហើយ ធ្វើម្តេចរបររកស៊ីនោះនឹងចំរើនឡើងបាន បើទុកជាធ្វើពានទៅលើត្រូវទំនងថ្មកាលដែលគួរធ្វើ ក៏មិនរួចអំពីសេចក្តីលំបាក ៗ

៦) មនុស្សល្ងង់ មិនដែលបានសេចក្តីសរសើរ អំពីសំណាក់លោកអ្នកប្រាជ្ញណាមួយដល់ម្តងសោះ បើបានសេចក្តីសរសើរខ្លះតែពីសំណាក់មនុស្សដែលល្ងង់ជាងខ្លួន ៗ

ទោសនៃសេចក្តីល្ងង់ដែលនាំមកអធិប្បាយក្នុងទីនេះ ជាសេចក្តីសង្ខេបខ្លីដែលនៅមានតទៅទៀតជាសេចក្តីវែងឆ្ងាយទូលាយណាស់ ៗ ទោសនៃសេចក្តីល្ងង់នេះ មិនមែនមានតែក្នុងបច្ចុប្បន្ននេះទេ នឹងមានទៅក្នុងលោកឯមុខទៀតជាអនេក ៗ

ហេតុនេះគួរយុវជនទាំងឡាយ គប្បីញុំាងវិជ្ជានឹងទ្រព្យសម្បត្តិឲ្យកើតមានឡើង ឲ្យហាក់ដូចជាមិនចេះចាស់មិនចេះស្លាប់ នឹងគប្បីប្រ-

ញាប់ប្រព្រឹត្តសេចក្តីល្អ ឲ្យដូចជាមច្ចុរាជចាប់សក់ក្បាលទុកស្រេចហើយ ។

វិជ្ជារមែងឲ្យដឹងបទបាទមាត្រា បទបាទមាត្រារមែងឲ្យកើតគុណ គុណរមែងឲ្យកើតទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិរមែងឲ្យកើតធម៌ ធម៌ឲ្យកើតសុខ ដែលមនុស្សគ្រប់រូបត្រូវការប្រាថ្នាចង់បាន ។

សំដែងអំពីទោសនៃសេចក្តីល្ងង់ សូមបញ្ចប់សេចក្តីដោយសង្ខេបតែប៉ុណ្ណោះ ។ ឯវំ ។

ចប់វិទ្យុធម្មទេសនាកណ្ឌទី ៣ តែប៉ុណ្ណោះ ។

## បិសាចស្នេហា

# ឃ. និពន្ធមន្ត្រី ញ. ប៉ែម នៅព្រះរាជបណ្ណាល័យ កម្ពុជា

ជាអ្នកតែង

ម៉ឺង! ម៉ឺង! ម៉ឺង! ម៉ឺង! ម៉ឺង! សូរនាឡិកាធំនៅបន្ទប់រៀនមួយក្នុងវិទ្យាល័យ (លីសេ) ស៊ីសុវត្ថិ ម្ជុលខ្លីចង្អុលចំលេខ ៤ ម្ជុលវែងចង្អុលចំលេខ ១២ ប្រាប់ឲ្យដឹងថាដល់ម៉ោង ៤ ហើយ ជាពេលដែលត្រូវឈប់រៀនក្នុងវេលាល្ងាច ៗ រ៉ឺង! រ៉ឺង! សូរកណ្ដឹងក៏លាន់ឮឡើងបន្ទាប់ពីសូរនាឡិកា បណ្ដាគ្រូនិងសិស្សប្រុស - ស្រីក៏នាំគ្នាចេញពីវិទ្យាល័យដើរសំដៅទៅគេហដ្ឋានរៀងខ្លួន ៗ ក្នុងចំណោមសិស្សានុសិស្សអស់នោះ មានកុមារីស្ត្រីក្រមុំពីរនាក់ រូបឆោមស្រស់បស់ ជាទីគួរពិតពិលរមិលមើលនៃភ្នែកអ្នកផង នាងទាំងពីរកាន់សៀវភៅនៅដៃដើរចេញពីទ្វារមុខទន្ទឹមគ្នាតាមក្រោយពួកសិស្សប្រុសស្រីឯទៀត ៗ ដល់ផ្លូវប៉ូល្វ័រឌូដាដឺឡាក្រែនៅមុខសាលា ហើយក៏ដើរសំដៅទៅទិសខាងត្បូងតាមចិញ្ចើមថ្នល់នោះទៅ ៗ លុះនាងទាំងពីរដើររៀង ៗ មកដល់ផ្លូវមួយត្រង់ទៅខាងលិចឈ្មោះផ្លូវឲកញ៉ាម៉ែនក៏នាំបងប្អូនដើរសំដៅទៅខាងលិចដល់ទៅផ្លូវបត់ ស្រាប់តែមានបក្រយានយន្ត (ម៉ូតូស៊ីក្លូ) ១ បើកមកពីខាងត្បូងតាមផ្លូវនោះសំដៅទៅទិសខាងជើង ហើយមកដល់ជិតខ្លួននាងទាំងពីរ ត្រង់ផ្លូវបត់កាច់ជ្រុងនោះ នាងទាំងពីរក៏កើតភ័យស្រឡាំងកាំងដើរទៅមុខបន្តិចថយមក

ក្រោយបន្តិច ឯបុរសកំឡោះដែលជិះចក្រយានដោយខ្លាចប៉ះស្ត្រីទាំងពីរ ឬដោយគិតយ៉ាងណាមិនប្រាកដ, ស្រាប់តែកាច់ចង្កូតឡើងចំពោះមថ្នល់ ផល់ទីងសសរខ្សែលួសពុស្ទូរគ្រាំង! មនុស្សជិះខ្លួតធ្លាក់ទៅដេកស្រប៉ាប លើចំពោះមថ្នល់បែកក្បាលហូរឈាមមិនដាច់សន្ធប់បាត់ស្មារតីទៅ ។ ឯកុមារីទាំងពីរនាក់ក៏ស្រែកយ៉ូយវ៉ូយរ៉ាយ! ទាល់តែភ្ញាត់សំឡេង! លុះនាងបាត់ភិតភ័យស្រឡាំងកាំងហើយ ក៏ស្ទុះចូលទៅពិនិត្យអ្នករងគ្រោះមួយរំពេច, ឃើញមានឈាមហូរស្រោចដងខ្លួន, មិនកម្រើកដៃជើង, តែខ្លួននៅក្ដៅឧណ្ហៗ ដឹងច្បាស់ថា បុរសនោះគ្រាន់តែសន្ធប់មិនស្លាប់ទេ ។

ចួនជាវេលានោះស្ងាត់មនុស្សម៉ិនសូវមានអ្នកដើរត្រេចរង្គាត់ទៅមកច្រើនដូចសព្វដង, មេឃងងឹត មានភ្លៀងស្រិចៗបន្តិចផង ទើបនាងសារីដាបង្ហុចសៀវភៅឲ្យទៅនាងសារុនជាប្អូនកាន់ ហើយក្រឡេកមើលនាយអាយមិនឃើញមានមនុស្សដទៃចូលមកជិតខាងក្បែរទីនោះសោះ នាងក៏ចាប់លើកបុរសកំលោះឲ្យអង្គុយឡើងតែមិនសម្រេច! ទើបនាងប្រាប់ទៅនាងសារុនថា ប្អូនដាក់សៀវភៅទុកសិនទៅរកហៅស៊ីក្លូមួយមកឆាប់ៗ ។

កាលនាងសារីដេញប្អូនឲ្យទៅរកហៅស៊ីក្លូបាត់ទៅនោះ នាងគន់រមើលបុរសកំលោះនោះ តាំងពីចុងសក់រហូតដល់ចុងជើង ពិនិត្យមើលមុខមាត់ស្រស់បស់ ប្រមាណអាយុប្រហែល ២៥ ឆ្នាំ ពាក់ស្បែកជើង

អង់គ្រេង់ព័ណ៌ខ្មៅខាត់ថ្នាំយ៉ាងរលោង ខោបាកង ការ៉េតក ចងក្រវាត់ ពាក់មួកសំបុក តាមដែលនាងពិនិត្យមើលរូបរាងសាច់ឈាមសព្វគ្រប់ទៅ សមជាអ្នកមានវង្សត្រកូល ។ នាងសារីគន់មើលសព្វគ្រប់ទៅក៏កើតចិត្តអាណិតអាសូរបុរសកំលោះនោះពន់ពេកដែលមានចិត្តក្លាហានអង់អាចស៊ូប្រថុយជីវិតជួយការពារខ្លួននាងមិនឲ្យដល់នឹងចក្រយានយន្ត ប្រសិនបើគេមិនកាច់បង្កិតឲ្យឡើងទៅលើចិញ្ចើមថ្នល់ទេ មុខជាដល់ខ្លួននាងប្អូននាងមិនខាន ហើយអាចនាំឲ្យអន្តរាយជីវិតឬបាក់ដៃជើងក៏សឹងជាពុំត្រូវ ។ នាងសារីនឹក ។ ទៅ កាន់តែមានចិត្តអាណិតច្រើនឡើង ៗ ហើយមានចិត្តស្នេហាចូលមកជ្រែកជាមួយផង ... ។

មួយស្របក់នាងសារុនហៅស៊ីក្លូមកបាន ២ ទើបនាងទាំងពីរពិគ្រោះគ្នាថា យើងត្រូវឲ្យដាក់ស៊ីក្លូទៅមន្ទីរពេទ្យ ឬមួយនាំទៅក្បែឯផ្ទះវិញ ? នៅទីបំផុត នាងបងសម្រេចសេចក្តីថាផ្ទះពេទ្យនៅឆ្ងាយណាស់ ផ្ទះយើងនៅជិតបង្កើយប្រហែល ១០ សសរខ្សែលួសប៉ុណ្ណោះ មិនអីទេ

អូន បើអូនខ្លាចលោកឪពុកលោកម្ដាយបន្ទោសទុកការៈឲ្យបងនិយាយដោះសារជំនួសអូន, អូនកុំភ្លេចណា ត្រូវឲ្យអ្នកជាក់ស៊ីក្លូដឹកអូសយកចក្រយានយន្តនេះនាំបណ្ដើរទៅផ្ទះជាមួយនឹងអូន ឯស៊ីក្លូឲ្យគេទុកផ្ញើនឹងអ្នកជិតខាងនេះសិនហើយត្រូវអូនកាន់យកសៀវភៅបងទៅផង កុំភ្លេច!

នាងសារីថាហើយក៏ម្នីម្នាឡើងជិះលើស៊ីក្លូមួយដោយប្រាប់អ្នកស៊ីក្លូឲ្យនាំគ្នាជួយលើកអ្នករបួសដាក់លើស៊ីក្លូរបស់នាង ហើយនាងបីត្រកងបុរសនោះនៅលើស៊ីក្លូនុ៎ះឯងដោយនាងឥតរង្កៀសបន្តិចឡើយ ។

ឱ! លោក-អ្នកទាំងឡាយអើយ! បើសន្មតខ្លួនលោកឬខ្លួនខ្ញុំបាទជាបុរសកំលោះនោះវិញ តើចិត្តគំនិតរបស់លោកឬរបស់ខ្ញុំបាទនឹងមានអាការស្រើបស្រៀវស្នេហាយ៉ាងណាទៅ! បើពងកាយនៅក្នុងរង្វង់ដៃដ៏សស្អាតទន់ភ្លន់ ថែមទាំងមានក្លិនទឹកអប់ក្រអូបឈ្ងុយឈ្ងប់សព្វសព៌ាង្គកាយ បើនឹងងើបមើលទៅចំរង់មុខក៏ល្អផូរផង់ដូចដួងចន្ទ្រានាថ្ងៃពេញបូណ៌មី នាងមានអាយុទើបចូលក្នុងឆ្នាំគំរប់១៨កំពុងពេញវ័យក្រមុំ ដូចបទុមផុះផុតពីវា-រី ដើម្បីទទួលរស្មីព្រះសុរិយា ។ ខ្ញុំបាទយល់ថាចិត្តលោក-អ្នកទាំងឡាយនឹងគំនិតរបស់ខ្ញុំបាទ សឹងមានបំណងត្រូវគ្នាថា ចង់ឲ្យបុរសកំឡោះនោះភ្ញាក់រលឹកដឹងខ្លួនឡើងក្នុងពេលនោះភ្លាមទៅ ដើម្បីនឹងគយគន់មើលអា-ការកិរិយារបស់បុរសស្ត្រីទាំងគូនោះតើគេនឹងធ្វើមុខមាត់ដូចម្តេចទៅអេះ?

ចំណែកខាងនាងសារុនជាប្អូនទឹកមួយម៉ៅតែក្នុងចិត្តថា បងអញនេះចំណាប់ណាស់ ពាំនាំយកចំណីស្រស់ទៅបាត់ ទុកក្រៀមក្រោះឲ្យឯង! មិនអីទេ! សារុននឹងប្តឹងលោកម្តាយឲ្យតាប់បងសារីឲ្យអស់ពីចិត្ត! ហើយនាងបង្គាប់ឲ្យអ្នកស៊ីក្លូដឹកចក្រយានយន្តនាំបណ្តើរទៅជាមួយនឹងនាង នៅវេលាដែលនាងសារីនាំអ្នករបួសជិះស៊ីក្លូទៅបាត់នោះ ។

កាលកន្លងមកបានប្រមាណ ៥ នាទីស៊ីក្លូដែលនាងសារ៉ាជិះក៏បានមកដល់គេហដ្ឋានមួយធំចំបង មានសរសេរអក្សរគួធំៗ ដាក់នៅមុខផ្ទះថា "គេហដ្ឋានបរិប្បូរសម្បត្តិ" ជាផ្ទះសង់តាមបែបសម័យថ្មី ល្អប្លែកជាងគេហដ្ឋាននានា នៅភូមិបឹងកាំង ឃុំលេខ ៥ ក្រុងភ្នំពេញ ។ ឯពួកមនុស្សម្នាបរិចារក្នុងផ្ទះនោះក៏ផ្អើលឆោឡោមកហោមរោមមើលខ្សឹបខ្សៀវសួរគ្នា ព្រោះជាហេតុកេទចំឡែកមិនធ្លាប់មាន ព្រោះចៅហ្វាយក្រមុំរបស់ខ្លួន ទៅនាំយកបុរសកំឡោះមុខមាត់ស្រស់បស់មិនដែលស្គាល់គ្នាសោះថែមទាំងមានបែកក្បាលហូរឈាមផង ។ ក្រោយនោះបន្តិចទើបនាងសារុនបានទៅដល់ទីនោះ ពួកបរិវារបានឃើញមនុស្សអ្នកធាក់ស៊ីក្លូដឹកចក្រយានយន្តនាំបណ្តើរទៅជាមួយនឹងនាងសារុនទៅដល់ ក៏កាន់តែងឹកងល់ច្រើនឡើង តែមិនមាននរណាហ៊ានដេញដោលសួររឿងរ៉ាវនោះឡើយ ។

នាងសារ៉ាក៏បង្គាប់មនុស្សក្នុងផ្ទះ ឲ្យជួយលើកបុរសនោះគ្រាន់ទៅដាក់នៅបន្ទប់ទទួលភ្ញៀវ នៅលើគ្រែមួយហើយឲ្យដាំទឹកក្តៅលាងរបួសដាក់ថ្នាំ តាមវិធីបឋមព្យាបាលរបស់ពេទ្យ នាងលាងឈាមដែលប្រឡាក់រាងកាយស្អាតហើយ ទើបនាងក្រមុំទាំងពីរយកថ្នាំហិតគ្រវៗនៅប្រមុះអ្នករបួស ហើយយកភួយគ្របឲ្យកក់ក្តៅ នាងទាំងពីរកំពុងតែខ្វល់ខ្វាយក្រោយព្យាបាលអ្នកជម្ងឺនោះ ស្រាប់តែឮសូររថយន្តមកចតនៅមុខផ្ទះ នៅ

កង់រថយន្តនោះ គឺលោកឧកញ៉ាបរិបូរសម្បត្តិនិងលោកស្រីជាភរិយារបស់លោកដែលជាមាតាបិតារបស់កុមារទាំងពីរប្រាណនោះ លោកទាំងពីរឃើញមនុស្សម្នាក្នុងផ្ទះឆោឡោបំប្លែកខុសធម្មតា លោកក៏រួសរាន់ឡើងទៅលើផ្ទះភ្លាម ស្រាប់តែឃើញជីតាទាំងគូរបស់លោកធ្វើបឋមព្យាបាលដល់បុរសកំឡោះនោះយ៉ាងប្រញាប់ប្រញាល់ លោកក៏ទឹកឆ្ងល់ទើបសួរទៅថា:

"សារី, សារុន, កូនស្រី កើតរឿងអ្វី ក៏ញាប់ដៃ-ជើងម្ល៉េះ?

"ប៉ា, ចា៎ះ, ទុ៎ះហ្ន៎! – នាងសារីចង្អុលទៅខាងអ្នកជម្ងឺ ។

"អើ! វាកើតហេតុកេទដូចម្តេច ? – លោកឧកញ៉ាឈ្ងោចសួរកូនក្រមុំរបស់លោក ។

"កើតឧប្បត្តិហេតុនឹងចក្រយានយន្តឈ្មោះអ្វីខ្ញុំមិនដែលស្គាល់គេទេ" ។

"ចុះហេតុអី ក៏មកដេកក្នុងទីនេះ?- លោកឧកញ៉ាជាបិតាកាន់តែសង្ស័យច្រើនឡើង ៗ ទើបនាងសារុនជាប្អូននិយាយសារសេព្វជំនួសនាងបងថា :

"គឺអ្នកបងសារីនិងខ្ញុំ កាលចេញពីវិទ្យាល័យស៊ីសុវត្ថិ នៅពេលដែលឈប់រៀន ក៏នាំគ្នាដើរមកតាមចិញ្ចើមថ្នល់ផ្លូវប៊ូល្វ័រខូដាដឺឡាក្រេ ដើម្បីត្រឡប់មកផ្ទះវិញ ដើរមកដល់ផ្លូវឧកញ៉ាម៉ែន មកខាងលិចដល់ផ្លូវកាច់ជ្រុង ស្រាប់តែជិះនេះ (ចង្អុលទៅអ្នករបួស) ជិះចក្រយានយន្តមកពី

ខាងត្បូងបានឲ្យសព្ទសញ្ញាសុំផ្លូវឬទេ ខ្ញុំទាំងពីរមិនបានឮ រថក្រយាន-យន្តមកជិតខ្លួនខ្ញុំណាស់ហើយ ទើបឮស្នូរសព្ទសញ្ញារំពងឡើង, ខ្ញុំទាំងពីរក៏ស្ទុះឈរស្រឡាំងកាំង ហើយដើរទៅមុខបន្តិច ថយក្រោយបន្តិច រថនោះក៏ឃើញបត់ទៅឆ្វេងបន្តិច ងាកមកស្តាំបន្តិច ដូចជាលេងស្វាដណ្តើមទី នៅប្រហែល ១ ហត្ថប៉ុណ្ណោះទើបដល់ខ្ញុំទាំងពីរនាក់ស្លាប់ នាងឈប់ដកដង្ហើមធ្វើកមុខស្លប់ស្លែងស្រៀវជាពន្លឹកគន់ហេតុភេទដែលកើតឡើងនោះ រួចនិយាយតទៅទៀតថា :

"ដោយហេតុអ្នកនេះ គាត់មានមេត្តាចិត្តគិតក្រែងដល់ខ្ញុំទាំងពីរឬយ៉ាងណាក៏មិនដឹង ស្រាប់តែរថក្រយានយន្តឡើងទៅលើចិញ្ចើមថ្នល់ ប៉ះនឹងសសរខ្សែលួសយ៉ាងខ្លាំង ទាល់តែបែកក្បាលសន្លប់ទៅ ហើយអ្នកបងនឹងខ្ញុំក៏ជួយគ្នាហៅស៊ីក្លូដាក់គាត់មករក្សាព្យាបាលនៅផ្ទះនេះ ព្រោះខ្ញុំនឹងអ្នកបងមានគំនិតគិតយល់ព្រមគ្នាថាត្រូវតែជួយសង្គ្រោះគាត់ ព្រោះគាត់មានបុណ្យគុណស៊ូប្រថុយលះបង់ជីវិតខ្លួន ដើម្បីឲ្យខ្ញុំទាំងពីរនាក់ផុតពីគ្រោះថ្នាក់អន្តរាយ" ។

ឯលោកស្រីជាមាតាក៏និយាយដែកឡើងក្នុងពេលនោះ ទំនងជាបន្ទោសផង ប្រដៅផងថា "យីអើ! កូនក្រមុំយើងទាំងគូនេះចំណាប់ណាស់តើ! បានរៀនសូត្រវិជ្ជាកាន់តែខ្ពស់ឡើង កាន់តែស៊ីវិលខ្លាំងណាស់ឡើង, ចេះសេពគប់ពប់កេប្រុសឈ្មោលទាំងមិនដែលស្គាល់មុខគ្នាម្តងផង ពោល

ទំនៀមទម្លាប់ច្បាប់ស្រីអស់រលីងរលង! ធម្មតាកុមារីស្រីក្រមុំដែលមានពូជអំបូរល្អ នៅតែងរក្សាកិរិយាឫកពាតាមសណ្ដាប់ច្បាប់ស្រី, ទុកជាដើរ ដេក អង្គុយ ឈរ ឬ និយាយស្ដីអ្វី គេតែងឲ្យសមរម្យតាមបែបភាពស្រី មិនដែលមានស្រីក្រមុំណា នាំប្រុសឈ្មោលមកឡើងផ្ទះសំបែងដូច្នេះទេ នេះ នែ! កូនស្រីមាសម្ដាយ! ផ្ទះពេទ្យពដការមាននៅក្នុងក្រុងនេះម្ដេចក៏មិននាំទៅពេទ្យ? ។

លោកស្រីជាមាតានិយាយមិនទាន់ចប់ លោកឧកញ៉ាជាបិតាក៏និយាយជ្រែកឡើងក្នុងខណៈនោះថា “ណ្ហើយ! រឿងកើតហួសទៅហើយ មិនបាច់ពោលពាក្យបន្ទោសអ្វីទេ, អើ, សារី កូនស្រីអាពុកបានឲ្យគេទៅអញ្ជើញគ្រូពេទ្យហើយឬនៅទេ?

“ចាះ ខ្ញុំឲ្យមុំកៈទៅអញ្ជើញគ្រូពេទ្យវេជ្ជសិទ្ធហើយ មិនទាន់ឃើញវិលមកវិញ”- នាងសារីឆ្លើយតបពាក្យបិតា ។

“នៅពេលដែលកំពុងជជែកមិនទាន់ចប់ ស្រាប់តែអ្នកជម្ងឺបើកភ្នែកប្រែខ្លួនមានស្មារតីឡើង ធ្វើភ្នែកឡឹនឡង់ដោយទឹកចង្ងល់ណាស់ យកដៃស្ទាបក្បាលរបួស ។ អ្នកទាំងអស់គ្នាក៏មានសេចក្ដីត្រេកអរ ប៉ុន្តែអ្នកដែលត្រេកអរជាងគេនោះ គឺនាងសារីនិងនាងសារុនកុមារីទាំងពីររបស់លោកឧកញ៉ាបរិបូរសម្បត្តិ ។ ចួនជាគ្រូពេទ្យក៏បានមកដល់ក្នុងពេលនោះភ្លាម ចាក់ថ្នាំកំឡាំងឲ្យ ហើយពិនិត្យមើលវិធីរុំមុខរបួសឃើញត្រឹមត្រូវហើយ

និយាយថា ជម្ងឺនេះមិនជាធ្ងន់ទេ ដែលដល់ទៅជាសន្លប់នោះ ព្រោះប៉ះទៅលើសរសៃប្រសាទសំខាន់របស់អវយវៈ, មិនអីទេនឹងសះជាជាឆាប់ បើមានអ្នកព្យាបាលចំណាប់ចំណួនបែបនេះផង . រឹតតែសះជាឆាប់រហ័សឡើងទៀត" ហើយគ្រូពេទ្យក្រឡេកមើលទៅកុមារីទាំងគូ, នាងទាំងពីរមានសេចក្ដីអៀនខ្មាសឡើងមុខក្រហមងាកមុខចេញទៅ គ្រូពេទ្យនិយាយតែប៉ុណ្ណោះក៏លាម្ចាស់ផ្ទះចុះទៅវិញទៅ ។

លោកឧកញ៉ា លោកស្រី នាងក្រមុំសារីសារុននាំគ្នាចូលទៅជិតអ្នកជម្ងឺ ។

"សូមទានមេត្តាប្រោសអត់ទោស, ហេតុដូចម្ដេចបានជាខ្ញុំបាទមកនៅទីនេះ? លោកមេត្តាដំណាលរឿងរ៉ាវឲ្យខ្ញុំបាទបានដឹងផង" - អ្នកជម្ងឺសួរដោយទឹកឆ្ងល់ខ្លួនឯងខ្លាំងណាស់ ។

លោកឧកញ៉ា- "កុំបាច់ទឹកឆ្ងល់ចង់ដឹងរឿងរ៉ាវអី គង់តែនឹងបានដឹងជាប្រាកដ ហ៎! ហិតថ្នាំនេះទៅនាំឲ្យមានកំឡាំងសម្ងំដេកទៅសិនចុះ គេនឹងរ៉ាយរឿងឲ្យស្ដាប់ជាក្រោយ" ។ អ្នកជម្ងឺនោះក៏ធ្វើតាមបង្គាប់ដោយស្រួលបានសម្ងំដេកលក់ទៅមួយស្របក់ទៀត ។

អស់លោក-អ្នកមើលរឿងនេះ គង់មិនទាន់បានជ្រាបថា "អ្នកជម្ងឺនោះគឺអ្នកណា ឈ្មោះអ្វី កូនចៅចៅពង្សអ្នកណា ? តាមដោយពិត អ្នកជម្ងឺនោះ ជាអ្នករាជការក្នុងក្រសួងយុត្តិធម៌ជាចៅក្រម ដែលរាជការទើប

តាំងពីអាយុ ២៥ ឆ្នាំមិនទាន់មានគ្រួសារនៅឡើយ ជាបុត្រលោកឧកញ៉ាសីហារាជ និងលោកស្រីឡាប ឃុំលេខ ១ ក្រុងភ្នំពេញនេះដែរ ឈ្មោះខុនចៅក្រមកំឡោះនេះគេច្រើនហៅថា លោកចៅក្រមវត្ត ដ្បិតមិនទាន់បានព្រះរាជទានងារស័ក្ដិនៅឡើយ ។

*
* *

លុះដល់ព្រឹកព្រាងស្វាងព្រះសុរិយា អរុណរះឡើងផុតពីជើងមេឃទិសខាងកើត ជាគ្រឿងសញ្ញាដាស់សព្វសត្វទាំងឡាយលើផ្ទៃផែនដីឲ្យភ្ញាក់រលឹកពីការដេកលក់ឈប់សម្រាកកន្លងវេលារាត្រី ។ បណ្ដាមនុស្សម្នាប្រុសស្រីក្នុងគេហដ្ឋានបរិបូរសម្បត្តិក៏ភ្ញាក់រលឹកឡើងរាល់គ្នា ឯលោកចៅក្រមវត្តក៏ភ្ញាក់រលឹកព្រមជាមួយនឹងគេដែរ; ក្រោយដែលបានបរិភោគបបរនាងនក់នឹងទឹកដោះគោស្រស់រួចស្រេចហើយ ក៏ហាក់ដូចជាមានកំឡាំងគ្រាន់បើ អាចក្រោកអង្គុយ ឈរឬនឹងដើរក៏បាន; លោកក៏ក្រាបលាព្រមទាំងសំដែងសេចក្ដីអរគុណច្រើនជាអនេក ចំពោះលោកឧកញ៉ាបរិបូរសម្បត្តិនិងលោកស្រីជាម្ចាស់ផ្ទះ ព្រមទាំងជីតាទាំងគូរបស់លោក ហើយចុះចាកផ្ទះនោះទៅ ។

ស្រាប់តែមានសុភាពបុរសពីរនាក់ដើរចូលមកយ៉ាងអង់អាច ហាក់ដូចជាអ្នកធ្លាប់ស្និទ្ធស្នាលនឹងស្ថានទីនោះ, បុរសទាំងពីរនាក់តែងខ្លួនយ៉ាងហ៊ឺហាកិរិយាបុកពាស់ដែងឲ្យដឹងថា ជាមន្ត្រីជាន់ខ្ពស់, ប៉ុន្តែ

ម្នាក់ក្មេង ម្នាក់ទៀតចាស់ ៗ បុរសចាស់នោះ មានសក់ស្កូវមួយៗ ច្រមុះខ្ពស់មុខមូលទម្រង់ពងក្រពើ ថ្ពាល់ផត មានពុកមាត់ខ្វីៗ សមនឹងវង្វង់មុខ ប្រមាណអាយុប្រហែល ៥០ ឆ្នាយ ៗ បុរសដែលក្មេងនោះ មានមុខមាត់ទីងទ្រន់ទ្រាយដូចគ្នា ប៉ុន្តែឥតពុកមាត់ ថ្ពាល់មិនផត មុខពេញ សំបុរស្បែកសស្អាតជាងបន្តិច ហើយរូបរាងមិនខ្ពស់មិនទាប ជាមធ្យមបុរស ទាំងនៅក្នុងវ័យកំឡោះប្រហែលអាយុ២៣-២៤ឆ្នាំប៉ុណ្ណោះ ៗ

លោកឧកញ៉ាបរិបូរសម្បត្តិ កាលគ្រឡេកមើលទៅឃើញលោកឧកញ៉ាកដបម្រើជាសំឡាញ់លោក ដើរចូលមកដូច្នោះក៏ស្រែកសួរជាប្រញាប់ថា "លោកម្ចាស់ថ្លៃអើយ! បាត់មុខមាត់យូរណាស់, ថ្ងៃនេះប្រហែលជាមានភ្ញៀវធំមិនខាន, អញ្ជើញមកខាងណោះ, អ្នកណាទុំមុខមាត់ដូចលោកម្ល៉េះ?

"នេះជាកូនច្បងរបស់ខ្ញុំបាទ លោកភ្លេចហើយឬ? នេះហើយគឺចៅឧត្តម" ៗ

"អីហ៎! ម៉េចក៏ធាប់ធាត់ធំអីម្ល៉េះ បាត់ពើសហើយឬចៅឧត្តម ឥឡូវនេះ" - លោកឧកញ៉ាម្ចាស់ផ្ទះនិយាយជខ្វជន្ទញលេង, ឯបុរសឈ្មោះឧត្តមឡើងមុខក្រហមដោយសេចក្ដីអៀនខ្មាស ៗ

លោកម្ចាស់ផ្ទះក៏នាំភ្ញៀវទាំងពីរនាក់ឲ្យចូលទៅអង្គុយនៅបន្ទប់ទទួលភ្ញៀវទាំងអស់គ្នា ហើយស្ងប់ស្ងាត់ទៅមួយស្របក់ ទើបលោក

ឧកញ៉ាម្ចាស់ផ្ទះពោលឡើងមុនគេថា "លោកអញ្ជើញមកនេះ មានធុរៈអ្វីដែរឬគ្មានទេ ?

"បាទ, មានខ្លះ គឺចៅឧត្តម កូនប្រុសរបស់ខ្ញុំបាទនេះវាទទូចទទែរឲ្យខ្ញុំបាទ ស្ទើរតែរាល់ថ្ងៃ ឲ្យនាំបំណងរបស់វាមកជម្រាបលោកឲ្យបានជ្រាប" ។

"រឿងអ្វីអេះ! ចង់សុំធ្វើការក្នុងក្រសួងរបស់ខ្ញុំ ឬមួយត្រូវការពឹង...?

"មិនមែនដូច្នោះទេ, តានប្រុស ចៅឧត្តមប្រឡងជាប់ទីក្រមការពីឆ្នាំទៅ ឥឡូវបានទៅធ្វើបាឡាត់ស្រុក នៅស្រុកទូកមាស ខែត្រកំពត បានទទួលប្រាក់បៀវត្ស ១ ខែជាង ១១០ រៀលហើយ តានប្រុស ។

"ពូកែមែន! ខ្ញុំឃើញចៅឧត្តមរត់លេងប្រលែងគ្នាកាលពីប៉ុន្មានឆ្នាំនេះឯង ឥឡូវស្រាប់តែបានធ្វើជាមន្ត្រីបានប្រាក់ខែក្នុង ១ ខែជាង ១០០ រៀល មានភ័ព្វវាសនាមែន បន្តិចទៀតនឹងបានយសស័ក្តិជាឧកញ៉ាអ្វីជំនួសលោកឪពុកតវង្សត្រកូល, តែលោកឧត្តមកុំភ្លេចឧកញ៉ាបរិបូរសម្បត្តិដែលធ្លាប់រាប់អានគ្នាមកយូរហើយណា៎ះ! លោកឧកញ៉ាម្ចាស់ផ្ទះនៅតែជន្ទូជន្ទេញលេងលោកបាឡាត់ឧត្តមដដែល, ហើយលោកមានប្រសាសន៍តទៅទៀតថា "ចុះក្មួយមានរឿងសំខាន់អ្វីនឹងនិយាយជាមួយនឹងពូដែរឬ? និយាយចុះតាមចិត្ត កុំបារម្ភអី" ។

លោកបាឡាត់កំឡោះនៅតែអង្គុយស្ងៀម ហាក់ដូចជានៅមិនទាន់បាត់អៀនខ្មាស ទឹកមុខក្រហម ស្លឹកត្រចៀកទាំងសងខាងក៏ក្រហម ព្រោះតែសំដែងអាការញញឹមញញែម ៗ ទើបលោកឧកញ៉ាជាបិតាឆ្លើយឡើងជំនួសថា "គឺមិនមានរឿងអ្វីក្រៅទេ ទានព្រោស, ក្មេងក្នុងវ័យនេះច្រើនតែជួបប្រទះនឹងសេចក្ដីមេត្រីស្នេហាខាងកាមារម្មណ៍ ដែលជាវិស័យរបស់លោកិយជនហ្នឹងឯង" ៗ

"ហ៊ឺ ! ហ៊ឺ ! លោកក្មួយឧត្តមចង់បានប្រពន្ធ! លោកម្ចាស់ផ្ទះសើចកក្អាកកក្អាយហើយថា "អើចុះស្រឡាញ់នាងណា នៅទីណា? ទុកធុរៈឲ្យខ្ញុំធ្វើជាអ្នកផ្ទួរចៅមហាទៅដណ្ដឹងឲ្យកុំព្រួយឲ្យសោះ! ៗ

លោកបាឡាត់ឧត្តមនៅតែផ្ចប់មុខ ដោយអៀនខ្មាសផងដែល មិនឆ្លើយតបទៅម្ចាស់ផ្ទះថាអ្វីឡើយ ៗ ទើបលោកឧកញ៉ាជាបិតាឆ្លើយជំនួសថា "ទានព្រោស, លោកមិនទាន់បានប្រាប់រឿងរ៉ាវរបស់ឧត្តមទេ គឺកាលពីប៉ុន្មានខែកន្លងមកហើយនោះ ហាក់ដូចជាលោកធ្លាប់ដែលបានអញ្ជើញទៅមើលកីឡាយុវជនខ្មែរ ដែលមានពួកអ្នកទាត់បាល់ស្ដ្រីយួនមកពីដែនកូសាំងស៊ីន ដើម្បីសំដែងសេចក្ដីក្លាហានរបស់យុវនារីជាតិយួនតទល់នឹងយុវជនជាតិខ្មែរ ៗ នៅវេលាគ្រានោះមានប្រជាជនជាតិយួន, ចិន បារាំង ខ្មែរ, ទាំងប្រុស - ស្រីទៅមើលបាល់ឡើងយ៉ាងណែនណាន់តាន់តាប់ ឯខ្ញុំ

បាទមិនបានទៅនឹងគេទេ ប៉ុន្តែឧត្តមនេះវាបានទៅមើលហើយឈរនៅក្បែរលោកផង" ។

លោកឧកញ៉ាម្ចាស់ផ្ទះអង្គុយនឹកមួយស្របក់ក៏បញ្ចេញវាចាថា "ឱ! ខ្ញុំនឹកឃើញហើយ គ្រានោះខ្ញុំបានទៅនឹងគេដែរ បានទាំងនាំកូនក្រមុំខ្ញុំទាំងគូទៅជាមួយផង" ។

"ហ្នឹងហើយ ទានព្រោះ, ឧត្តមកូនខ្ញុំបាទនេះ តាំងអំពីថ្ងៃបានជួបប្រទះនឹងនាងសារុនវេលាណា ក៏កើតចិត្តប្រតិព័ទ្ធស្នេហាគ្មានដាច់ ត្រឡប់មកដល់ផ្ទះវិញមិននិយាយស្ដីនឹងអ្នកឯណាមួយម៉ាត់ ពុំតែស្ងួរមាត់និយាយរអ៊ូរទាំតែម្នាក់ឯង ដូចជាមនុស្សខ្មោចចូល, លុះខ្ញុំបាទដេញដោលសួរណាស់ទៅ ទើបប្រាប់ត្រង់ថា ស្រឡាញ់នាងសារុន កូនក្រមុំលោក; រឿងរ៉ាវរបស់ចៅឧត្តមត្រឹមប៉ុណ្ណោះឯង" ។

"បើនិយាយឲ្យខ្លីទៅ គឺថាតាំងពីថ្ងៃនោះរហូតមកដល់ថ្ងៃនេះ បាឡាត់ឧត្តមជាប់ចិត្តស្រឡាញ់ស្អិតចំពោះលើរូបនាងសារុន ជាកូនក្រមុំខ្ញុំដូច្នោះឬ ?-លោកឧកញ៉ាម្ចាស់ផ្ទះសួរបញ្ជាក់ ។

"បាទ" -លោកឧកញ៉ាពជបំរើតប ។

"តាំងពីថ្ងៃនោះមកទើបខ្ញុំបាទនិយាយល្បួងលោមរម្ងាប់សេចក្ដីស្នេហា ហើយមានខសន្យាថា បើឯងខំរៀនសូត្ររហូតដល់បានប្រឡងជាប់ទីក្រមការ បានចូលធ្វើរាជការមានបៀវត្សប្រាក់ខែល្មមចិញ្ចឹមប្រពន្ធកូន

បានវេលាណា អាពុកនឹងចាត់ការដណ្ដឹងឲ្យ; ហេតុនេះហើយបានជាគាំងពីចេញទៅធ្វើជាបាឡាត់ស្រុកវេលាណា ចេះតែខំទូចម៉ង់ដែលខានមួយថ្ងៃ ដើម្បីឲ្យខ្ញុំបានមកជួបនឹងលោក ស្ដាប់ប្រសាសន៍លោកមើល តើលោកមានយោបល់ដូចម្ដេចក្នុងរឿងនេះ ?

លោកម្ចាស់ផ្ទះងាកទៅសួរបញ្ញាក់ម្ចាស់ខ្លួនថា "ម៉េចហ៎, កយូរុគ្គម ចាប់ចិត្តស្រឡាញ់សារុនណាស់ទៅពិតមែនឬ? ។

គ្រានេះ លោកបាឡាត់រុគ្គមស្ទុះក្រោកឡើងទៅក្រាបសំពះនៅចំពីមុខលោកឧកញ៉ាបរិបូរសម្បត្តិហើយពោលពាក្យជម្រាបថា "បាទ, តានប្រែស ខ្ញុំបាទស្រឡាញ់ប្អូនសារុនពិត ៗ លើសលែងជាងជីវិតរបស់ខ្ញុំបាទទៅទៀត ខ្ញុំបាទចាប់ចិត្តស្នេហាដោយដួងចិត្តដ៏បរិសុទ្ធ ហើយខ្ញុំបាទបានប្ដេជ្ញាទុកក្នុងចិត្តជាស្រេចថា ប្រសិនបើមិនបានរៀបមង្គលការជាគូនឹងប្អូនសារុនទេ មុខជាខ្ញុំបាទស៊ូលះបង់ជីវិត ដើម្បីសំដែងឲ្យឃើញសេចក្ដីសុចរិតស្មោះត្រង់របស់ខ្ញុំបាទក្នុងលោកនេះ ឲ្យបានឃើញជាក់ស្ដែងប្រាកដ ។

លោកឧកញ៉ាម្ចាស់ផ្ទះដកដង្ហើមធំហើយនិយាយជាទំនងមិនឲ្យបាក់បែកមេត្រីសេចក្ដីរាប់អានថា "ចំណែកខាងខ្ញុំឥតយល់ទាស់បន្តិចអំពីរឿងនេះ គ្រាន់តែរូបលោកកយូដែលទុកដូចជាកូនទៅស្រាប់ទៅហើយ សូម្បីអ្នកដទៃទៀតមកដណ្ដឹង ខ្ញុំក៏ស៊ូត្រិះគិតលើកឲ្យដែរ ប៉ុន្ដែការនេះពុំមិន

ស្រេចនៅលើខ្លួនខ្ញុំទេ   ការសំខាន់ស្រេចនៅលើម្ចាស់ខ្លួនគេទេតើ ចាំខ្ញុំសាកសួរចិត្តកូនមើលសិន   ខ្ញុំមិនហ៊ានបង្ខំចិត្តគេទេ   បុរាណលោកពោលថា “សង់ផ្ទះតោងតាមចិត្តអ្នកនៅ” មែនទេ? មួយទៀតលោកថា “ចង្អៀតទីចង្អៀតចុះ កុំឲ្យតែចង្អៀតចិត្ត” មែនទេ?

“ពិតដូចមានប្រសាសន៍, រឿងនេះស្រេចនៅសាមីខ្លួនគេជាប្រមាណ”- លោកឧកញ៉ាពជបំរើពោលអនុលោមតាមពាក្យលោកឧកញ៉ាម្ចាស់ផ្ទះ ។

“រឿងនេះទុកថ្ងៃក្រោយចុះ កញ្ញឧត្តម ចាំឲ្យខ្ញុំសួរចិត្តគេសិន” ។

“បាទ, ខ្ញុំបាទសូមអរគុណជាទីបំផុត” — លោកបាឡាត់ស្រុកកំឡោះលើកដៃសំពះដោយកិរិយាគោរពទន់ភ្លន់ចំពោះលោកឧកញ៉ាជាម្ចាស់ផ្ទះ ។ ក្រោយនោះបន្តិចឪពុកនិងកូនក៏លាលោកម្ចាស់ផ្ទះចុះពីគេហដ្ឋានបរិបូរសម្បត្តិនោះទៅ ។

* * *

ឯអ្នកដែលមាននាមថា លោកចៅក្រមវ័ត្ថនោះ កាលបានត្រឡប់ទៅដល់លំនៅរបស់ខ្លួនហើយ ក៏ខំថែរក្សារបួសនោះទាល់តែសះជាស្រឡះ តែចិត្តគំនិតអណ្តែតអណ្តូងរវើរវាយ ដោយហេតុវង់ភក្ត្រផូរផង់របស់នាងក្រមុំទាំងគូនោះ មកជាប់នៅនឹងភ្នែករបស់លោកចៅក្រមកំឡោះជានិច្ច នាំឲ្យលោកចៅក្រមកំឡោះចាប់ចិត្តប្រតិព័ទ្ធស្នេហាតាំងពីថ្ងៃនោះមក;

គ្រានេះជាគ្រាដំបូង ដែលលោកវ័ត្តលុះក្នុងអំណាចនៃសេចក្ដីស្នេហាគ្រា តែដកខ្លួនមិនរួច, ក្នុង ២៤ ម៉ោង លោកវ័ត្តតែងនាំយករឿងឧប្បត្តិហេតុ នោះមកគិតមកនឹកតែម្នាក់ឯង, ជួនកាលឡើងទឹកមុខស្រស់ញញឹមប្រិមប្រិយ ជួនកាលស្រពោនស្រពាន់ក្រៀមក្រោះ នាំឲ្យអ្នកផងដែលនៅក្នុងផ្ទះជាមួយមានសេចក្ដីងឿងឆ្ងល់កល់គ្នា តែឥតនរណាមួយដឹងរឿងរ៉ាវនោះឡើយ ទាំងលោកចៅក្រមវ័ត្តក៏មិនបានបញ្ចេញរឿងរ៉ាវរបស់ខ្លួនឲ្យអ្នកដ-ទៃបានដឹងមួយជាពីរឡើយ លាក់ទុកតែក្នុងចិត្ត ក្រែងមិនបានសម្រេចនាំឲ្យខ្មាសគេ ប៉ុន្តែព្យាយាមរកឱកាសចន្លោះ ដើម្បីឲ្យបានជួបនឹងនាងក្រមុំសារី ហើយថ្លែងបំណងរបស់ខ្លួនឲ្យនាងបានដឹងសេចក្ដីពិតក្នុងចិត្តផង ។

ចំណែកខាងនាងក្រមុំសារី នឹងនាងក្រមុំសារុនបងប្អូនទាំងពីរនាក់ តាំងពីថ្ងៃនោះកន្លងមក ចិត្តគំនិតរបស់នាងមិនបានជាប់នៅនឹងខ្លួនប្រាណ ហាក់ដូចព្រះកាមទេពបានថ្លែងសរត្រូវត្រង់ទរប្រទេសរបស់នាងក្រមុំទាំងគូដោតជាប់នៅនឹងបេះដូង ធ្វើឲ្យចិត្តចេតសិករបស់នាងអណ្ដែតអណ្ដូងទៅតាមអំណាចកាមារម្មណ៍ នឹករលឹកទៅរកតែបុរសកំឡោះនោះពល់ទិវារាត្រីពុំដែលដាច់ ។

☼

☼ ☼

កាលព្រះសុរិយាជ្រៀងជ្រេជិតអស្ដង្គតមុនចូលកាន់សន្ធ្យាព្រី រស្មីព្រះអាទិត្យឆ្លុះពន្លឺក្រហមច្រាលឆ្ពោះទៅលើផ្ទៃមេឃ អ្នកផងក្រឡេក

មើលទៅហាក់ដូចជាព័ណ៌ឈាម ៗ នៅឱកាសនេះហើយដែលនាងក្រមុំសារុនចុះពីគេហដ្ឋានទៅអង្គុយលេងនៅក្នុងសួនច្បារក្រោយផ្ទះ ដ៏ដេរដាស ដោយផ្កាកុឡាប, ច័ន្ទន៍ក្រតិ សឹងមានក្លិនក្រអូបឈ្ងុយឈ្ងប់ផ្សព្វផ្សាយពេញបរិវេណសួនច្បារ នាងសារុនក៏អង្គុយលើកៅអីវែងមួយ ក្អែកក៏រំពៃមើលបុប្ផាផ្កានានា ដោយអាការស្រស់បស់ ស្រាប់តែលេចបាឡាត់ស្រុកកំឡោះដែលមាននាមថា ឧត្តមដើរចូលមកយ៉ាងស្ងប់ស្ងាត់ សំដៅត្រង់មកចំពោះមុខនាង ហើយបង្អោនកាយសំដែងសេចក្តីគោរព ហើយពោលពាក្យជាទំនងអង្វរថា :

“ប្អូនសារុន! ថ្ងៃនេះបងមានសង្ឃឹមថាប្អូននឹងថ្លែងសេចក្តីក្នុងចិត្តប្រាប់បងឲ្យបានដឹងជាប្រាកដ នៅវេលាគ្រានេះជាពុំខាន! ៗ

នាងក្រមុំសារុនភ្ញាក់ព្រើតទាំងខ្លួនប្រាណ ហើយនិយាយឆ្លើយឆ្លងដោយសេចក្តីឆ្ងាប់កប់អានថា “ចុះលោកឲ្យខ្ញុំអាណិតមេត្តាប្រាប់សេចក្តីពិតអ្វី? លោកបាឡាត់, ខ្លួនខ្ញុំឥតមានរឿងស្ងាត់កំបាំងអ្វីលាក់ទុកក្នុងចិត្តទេ” ៗ បាឡាត់ស្រុកធ្លាក់ទឹកមុខមួយរំពេច ហើយនិយាយស្ទើរតែទៅជាខ្សឹបថា :

“ប្អូនសារុនអើយ! — ឈប់ដកដង្ហើមវែង ហើយនិយាយតទៅទៀតថា “ប្អូនបានសញ្ញានឹងបងថានឹងឆ្លើយប្រាប់ឲ្យបងបានដឹងក្នុងថ្ងៃនេះមិនមែនឬ?

(មានត)

# កុម្ភជាតក

សំដែងអំពីដើមកំណើតសុរានិងទោសនៃសុរា

## លោកអាចារ្យ ឈឹម-ស៊ុម (សទ្ធម្មបញ្ញោ)

គ្រូបង្រៀននៅសាលាបាលីជាន់ខ្ពស់ ប្រែនិងរៀបរៀងតាម គម្ពីរខុទ្ទកនិកាយ ព្រមទាំងអដ្ឋកថា ។

### អារម្ភកថា

កុម្ភជាតកនេះ ជាជាតក ១ ដែលមានប្រាកដក្នុងព្រះត្រៃបិដក គម្ពីរខុទ្ទកនិកាយជាតក តឹសនិបាត ជាភាសាបាលី ខ្ញុំបានប្រែនិងរៀបរៀងសេចក្ដីជាខេមរភាសា ដោយសេចក្ដីត្រូវការរបស់លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

ក្នុងវេលាដែលខ្ញុំប្រែនិងរៀបរៀងនោះ ខ្ញុំបានពិនិត្យយកសេចក្ដីពីគម្ពីរអដ្ឋកថានៃគម្ពីរនេះមកដាក់បញ្ចូលផង ដើម្បីឲ្យទាក់ទងសេចក្ដីគ្នា ជាលំអានល្មមស្ដាប់បានដោយងាយ ។ ឯសេចក្ដីដែលពោលតាមគម្ពីរខុទ្ទកនិកាយជាតក តឹសនិបាតនោះ ខ្ញុំដាក់ទាំងបាលីព្រមទាំងសេចក្ដីប្រែជាសម្រាយផង ឥតមានរំលងត្រង់គាថាណាមួយឡើយ រួមទាំងអស់ ៣១ គាថា តែសេចក្ដីប្រែនោះមិនមែននិយមព្យញ្ជនជាប្រមាណទេ ប្រែនិយមយកអត្ថរសជាប្រមាណ តាមទំនងសេចក្ដីនៃគម្ពីរអដ្ឋកថា ។

ខ្ញុំខំចៀតធ្វើរឿងនេះ ក្នុងពេលឱកាសមួយស្របក់ៗ ដែលក្រៅអំពីពេលធ្វើការជាប្រក្រតី ដរាបតែចប់សព្វគ្រប់ ហើយបានយកទៅប្រគេនព្រះតេជ-គុណព្រះសិរីសម្មតិវង្ស ព្រះនាម "ឯម" ចាងហ្វាងសាលាបាលីជាន់ខ្ពស់ និងជាអធិបតី ក្រុមជំនុំព្រះត្រៃបិដក ដែលជាធម្មាចារ្យរបស់ខ្ញុំ និងព្រះតេជ-គុណព្រះឧត្តមមុនី ព្រះនាម "ស៊ូ" អធិបតីរងក្រុមជំនុំ ព្រះត្រៃបិដក សូមឲ្យលោកពិនិត្យឲ្យ លោកក៏បានពិនិត្យឲ្យដោយសេចក្តីមេត្តា ហើយខ្ញុំយករឿងនេះទៅជូនលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ឲ្យលោកចាត់ចែងការបោះពុម្ព ដើម្បីផ្សាយដល់ពួកពុទ្ធសាសនិកជន គ្រប់តម្បន់ដែលមានសេចក្តីត្រូវការ ។

ខ្ញុំសូមប្រគេនបុញ្ញរាសី ដែលកើតអំពីវីរិយភាពរបស់ខ្ញុំនេះទាំងអស់ចំពោះព្រះតេជ-គុណទាំងពីរព្រះអង្គនោះ ដើម្បីជាបតិការតបព្រះគុណដ៏ធំទូលាយ សូមឲ្យព្រះគុណបានសម្រេចនូវឥដ្ឋមនុញ្ញផលតាមគាប់ព្រះទ័យ ហើយសូមសេចក្តីសុខ-ចំរើនមានដល់ខ្ញុំផង ដល់លោកអ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់អស់លោក-អ្នកដែលប្រព្រឹត្តតាមព្រះពុទ្ធសាសនាផង អស់កាលជាអង្វែងទៅហោង ។

លោកអាចារ្យ ឈឹម-ស៊ុម នៅវត្តលង្កា ក្រុងភ្នំពេញ ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៗ

គោចាតុកសិតំ ឥទំ ធម្មទេសនំ សត្ថា ជេតវនេ វិហារន្តោ វិសាខាយ សហាយិកា សុរាបីតា បញ្ចសតា ឥត្ថិយោ អារព្ភ កថេសិ ៗ

កាលដែលសម្តេចព្រះសាស្តាចារ្យជាម្ចាស់ ព្រះអង្គទ្រង់សម្រាន្តព្រះឥរិយាបថនៅវត្តជេតពន ទ្រង់ប្រារព្ធនូវស្រីប្រាំរយនាក់ដែលជាសំឡាញ់នឹងនាងវិសាខា ជាស្រីផឹកសុរា ហើយទ្រង់ត្រាស់សំដែងនូវព្រះធម៌ទេសនាមានបទថា គោចាតុកសិ ដូច្នេះជាដើម ៗ

បានឮមកថា: មនុស្សទាំងឡាយលេងមហោស្រពផឹកសុរាកងរំពងក្នុងនគរសាវត្ថី ស្រីៗទាំងប្រាំរយនោះ ចាត់ចែងសុរាជូនស្វាមីដែលកំពុងលេងមហោស្រព រួចស្រេចហើយ ក៏គិតគ្នាថា: "យើងនឹងលេងមហោស្រព" ហើយក៏ទៅបបួលនាងវិសាខាៗប្រកែកថា: "មហោស្រពនេះគេលេងផឹកសុរា ខ្ញុំមិនផឹកសុរាទេ" ស្រីទាំងនោះនិយាយថា: "សូមនាងថ្វាយទានចំពោះព្រះសម្មាសម្ពុទ្ធចុះ យើងនឹងលេងមហោស្រព" ៗ នាងវិសាខាទទួលព្រមថា: "ស្រួលហើយនាង" ហើយឲ្យគេនិមន្តសម្តេចព្រះសាស្តាចារ្យមក នាងបានថ្វាយមហាទាន លុះដល់សាយណ្ហសម័យថ្ងៃរសៀល នាងកាន់យកគ្រឿងក្រអូបនឹងផ្កាកម្រងជាច្រើន ស្រីៗទាំងនោះក៏ហែហមចោមរោមជាបរិវារ យាត្រាទៅកាន់វត្ត

ជេតពនដើម្បីស្តាប់នូវធម្មកថា ៗ ឯស្រីទាំងនោះទៅឈរទៀបក្លោងទ្វារ ផឹកសុរារួចស្រេចហើយទើបបានចូលទៅកាន់សំណាក់សម្តេចព្រះសាស្តា ជាមួយនឹងនាងវិសាខា ៗ ថ្វាយបង្គំសម្តេចព្រះសាស្តាហើយក៏អង្គុយនៅ ក្នុងទីគួរមួយ ៗ បណ្តាស្រីទាំងនោះ ស្រីពួកខ្លះរាំ ស្រីពួកខ្លះរាស់ដៃរាស់ ដើងកើតជារឿងឈ្លោះប្រកែកក្នុងសំណាក់ព្រះបរមសាស្តាចារ្យ ព្រះអង្គ ក៏ទ្រង់បញ្ចេញនូវព្រះរស្មី អំពីព្រះភមុកាលោម (រោមចិញ្ចើម) ដើម្បីឲ្យ ស្រីទាំងនោះកើតសង្វេគតក់ស្លុត ក៏កើតជាអ័ព្ទងងឹតជិតសព្វទិសានុទិស ៗ ស្រីទាំងនោះក៏កើតភ័យរន្ធត់តក់ស្លុតមហិមា ដោយសារមរណភ័យមក គម្រាម ៗ សុរាក៏សាបរលាបទៅភ្លាមព្រោះតែភ័យនោះ ៗ សម្តេច ព្រះដ៏ទ្រង់យស ទ្រង់កៀសចេញអំពីបល្ល័ង្កដែលទ្រង់គង់ ទៅប្រថាប់ នៅលើកំពូលភ្នំព្រះសុមេរុ ហើយទ្រង់បញ្ចេញនូវព្រះរស្មីអំពីព្រះឧណ្ណាលោម (រោមប្រជុំចិញ្ចើម) ពន្លឺក៏ចែងចាំងហាក់ដូចជាព្រះចន្ទនឹងព្រះ អាទិត្យ ១ ពាន់រះឡើង ៗ ព្រះអង្គទ្រង់ប្រថាប់នៅលើកំពូលភ្នំព្រះ សុមេរុនោះ ហើយទ្រង់សំដែងនូវបទព្រះគាថា ដើម្បីឲ្យស្រីទាំងនោះ កើតសង្វេគថា :

កោ នុ ហាសោ កិមានន្ទោ
និច្ចំ បជ្ជលិតេ សតិ ?

កាលបើលោកសន្និវាសនេះ ភ្លើងទាំង ១១ កង[1]ឆេះឡើងសន្ធោសន្ធៅជានិច្ច (យ៉ាងនេះ) តើនាងទាំងឡាយសើចដូចម្ដេចកើត: ត្រេកអរដូចម្ដេចកើត?

អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ

នាងទាំងឡាយពិតជាងងឹតគឺអវិជ្ជាដែលមានវត្ថុ ៨ ប្រការ[2]គ្របសង្កត់ហើយ ម្ដេចឡើយក៏មិនស្វែងរកប្រទីបជាលា ពោលគឺប្រាជ្ញាដើម្បីកំចាត់បង់នូវងងឹតនោះចេញ ។

លុះចប់ព្រះគាថាហើយ ស្រីទាំងប្រាំរយនោះ ក៏បានដល់នូវសោតាបត្តិផល ។ សម្ដេចព្រះទសពល ទ្រង់និមន្តមកវិញ ហើយគង់នៅលើព្រះពុទ្ធាសនៈ ក្រោមម្លប់គន្ធកុដី ។ សម័យនោះនាងវិសាខាថ្វាយនូវនមស្ការព្រះអង្គរួចស្រេច ក៏ក្រាបបង្គំទូលថា: សូមទ្រង់ព្រះមេត្តាប្រោស ការផឹកសុរានេះ ជាការទម្លាយនូវហិរិឱត្តប្បៈ (មិនឲ្យមានសេចក្ដីអៀនខ្មាសខ្លាចបាប) តើសុរានេះកើតពីត្រឹមណាមកព្រះអង្គ? ទើបទ្រង់នាំអតីតនិទានមកសំដែងប្រាប់នាងវិសាខាថា:

---

១ ភ្លើងគឺ រាគ, ទោស, មោហ, ជាតិ, ជរា, មរណ, សោក, បរិទេវ, ទុក្ខ, ទោមនស្ស, ឧបាយាស ។ ២ មិនដឹងសេចក្ដីទុក្ខ, មិនដឹងហេតុនៃសេចក្ដីទុក្ខ, មិនដឹងសេចក្ដីរលត់ទុក្ខ, មិនដឹងផ្លូវនៃសេចក្ដីរលត់ទុក្ខ, មិនដឹងអតីត, មិនដឹងអនាគត, មិនដឹងទាំងអតីតទាំងអនាគត, មិនដឹងបដិច្ចសមុប្បាទ ។

អតីតេ កាលេ កាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រ១ ព្រះអង្គទ្រង់ព្រះនាម ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្រុងពារាណសី (សម័យនោះ) មានជើងព្រៃម្នាក់ឈ្មោះសុរៈ នៅក្នុងកាសិករដ្ឋ គាត់បានទៅព្រៃហេមពាន្តដើម្បីស្វែងរកគ្រឿងកណ្ឋជផ្សេងៗ ។ នៅព្រៃហេមពាន្តនោះមានឈើ ១ ដើម ដុះឡើងកំពស់ ១ ជំហរ ហើយបែកប្រគាបជា ៣ កងបន្ទោះប្រគាបទាំង ៣ នោះមានរណ្ដៅទំហំប៉ុនពាង លុះដល់ទឹកភ្លៀងធ្លាក់មកកកដក់ទឹក ពេញក្នុងរណ្ដៅនោះ ហើយមានដើមស្រមៃ, កន្ទួតព្រៃនឹងម្រេច ដុះជិតរបរិគដើមឈើនោះ ផ្លែពាំទុំជ្រុះធ្លាក់ចុះក្នុងរណ្ដៅនោះ មិនតែប៉ុណ្ណោះ សត្វសេកទាំងឡាយ ក៏ពាំនាំយកគួរគួរនៃស្រូវសញ្ញាតសាលី អំពីទីជិតខាងមកទំស៊ីនៅលើដើមឈើនោះ គ្រាប់ស្រូវនឹងអង្ករ ក៏ធ្លាក់ចុះក្នុងរណ្ដៅនោះទៀត ។ ហេតុដូច្នោះទឹកនោះលុះត្រូវកំដៅព្រះអាទិត្យក៏មានពណ៌ក្រហម មានរសខ្លាំងឡើង ៗ ក្នុងនិទាឃសម័យ (រដូវក្ដៅ) សត្វបក្សីមានសេចក្ដីស្រេកឃ្លានបានមកផឹកទឹកនោះ ហើយស្រវឹង បម្រះនទៀលដេប់ដួលដេកនៅទៀបគល់ឈើ លុះដេកបន្តិចទៅ ហើយក៏ស្រែកកញ្ជ្រៀវខ្ទៀវខ្ទ្រាហើររចៀសចេញទៅ ។ សម្បីសត្វកំប្រុកនឹងស្វាជាដើម ក៏មានទំនងដូច្នោះដែរ ។

នាយព្រៃពេញបានឃើញទឹកនោះហើយក៏គិតថា ទឹកនេះ បើជាទឹកពុល សមជាសត្វទាំងនេះស្លាប់ ប៉ុន្តែសត្វទាំងនេះ គ្រាន់តែផឹកបន្តិចហើយក៏ទៅដោយស្រួលទៅ ទឹកនេះមិនមែនជាទឹកពុលទេ្បីយ" ហើយគាត់ផឹកខ្លួនឯងគ្រាតែស្រវឹង ហើយមានចំណង់ចង់ស៊ីសាច់ គាត់ក៏បង្កាត់ភ្លើង ហើយសម្លាប់សត្វបក្សីទាំងឡាយមានទទាទីងមាន់ជាដើមដែលផ្ទប់ជួលនៅទៀបគល់ឈើ ចំអិនលើរងើកភ្លើងហើយកាំដៃម្ខាងស៊ីសាច់ ដៃម្ខាងនៅកងទីនោះអស់ពីរបីថ្ងៃ ។

សម័យនោះ មានតាបស ១ រូបឈ្មោះវរុណៈ នៅក្នុងទីជិតនោះ ។ ព្រៃពេញតែងតែទៅកាន់សំណាក់តាបសនោះ ហើយរំពឹងគិតថាៈ "បើអញផឹកទឹកនេះជាមួយនឹងតាបស (សមជាសប្បាយណាស់)" ហើយគាត់យកទឹកនោះ ១ បំពង់ឫស្សី ជាមួយនឹងដុំសាច់ដែលចំអិនស្រេច ដើរទៅកាន់បណ្ណសាលា ហើយនិយាយថាៈ "សូមលោកម្ចាស់ឆាន់ទឹកនេះលងមើល"។ តាបសនឹងព្រៃពេញទាំងពីរនាក់ ក៏នាំគ្នាទំពាសាច់ផឹកទឹកនោះៗ មានឈ្មោះថាទឹកសុរាផង ទឹកវរុណីផង ព្រោះហេតុដែលព្រៃពេញឈ្មោះសុរៈ នឹងតាបសឈ្មោះវរុណៈ បានឃើញ (មុនគេ) ។

អ្នកទាំងពីរគិតគ្នាថាៈ "នេះឯងជាឧបាយដ៏សំខាន់" ហើយក៏ដងដាក់ពេញបំពង់ឫស្សីជាច្រើន រែកទៅកាន់ស្រុកបច្ចន្តគ្រាម ឲ្យគេ

ក្រាបបង្គំទូលព្រះមហាក្សត្រថា: "មានអ្នកបេះផ្ញើទឹកស្រវឹងមកហើយ" ។ ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យហៅអ្នកទាំងពីរនាក់មក អ្នកទាំងពីរនាក់ក៏បង្អោនទឹកនោះចូលទៅក្រាបបង្គំថ្វាយ ។ ទ្រង់សោយទឹកសុកនោះពីរបីដងក៏ស្រវឹងមែន ។ ទឹកសុកនោះបានត្រឹមតែ ១ ថ្ងៃ ២ ថ្ងៃ ប៉ុណ្ណោះក៏អស់ទៅ ទើបទ្រង់ត្រាស់សួរថា: "ទឹកសុកនេះមានទៀតទេ ? អ្នកទាំងពីរនាក់ក្រាបបង្គំទូលថា: "បពិត្រព្រះសម្មតិទេព មានទៀត ។ ទ្រង់ត្រាស់សួរថា: "មាននៅឯណា ? អ្នកទាំងពីរនាក់ក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព មាននៅព្រៃហេមពាន្ត" ។ ទើបទ្រង់បង្គាប់ថា: "បើដូច្នោះចូរអ្នកទាំងឡាយទៅយកមកទៀត" ។ ជនទាំងពីរនាក់នោះទៅនាំយកទឹកសុកមកអស់វារម្តងពីរដងហើយគិតគ្នាថា: "យើងមិនអាចនឹងទៅយកអស់កាលជានិច្ចបានទេ" ហើយក៏កំណត់យកនៅគ្រឿងផ្សំគ្រប់មុខបានយកមកផ្សំធ្វើសុកនៅក្នុងព្រះនគរ ។ អ្នកនគរទាំងនោះនាំគ្នាផឹកសុកហើយក៏ទៅជាអ្នកមានសេចក្តីប្រមាទ ប្រហែសធ្វេសក្នុងការងារត្រឡប់ទៅជាអ្នកកំសត់ទុគ៌ត ព្រះនគរក៏ហាក់ដូចជាសូន្យ ឥតមានមនុស្សឥតមានសេចក្តីចំរើនដោយការងារណាមួយឡើយ ។ ហេតុដូច្នោះបានជាអ្នកធ្វើសុកនាំគ្នារត់ចេញអំពីទីនោះ ៖ ទៅកាន់នគរពារាណសីឲ្យគេក្រាបបង្គំទូលសម្តេចព្រះនរបតីថា: "មានអ្នកធ្វើសុកមកដល់ហើយ" ។ ព្រះរាជាទ្រង់

បង្គាប់ឲ្យហៅមក ហើយទ្រង់ព្រះរាជទានស្បៀងជាដើមទុនឲ្យធ្វើសុរាដូច្នោះទៀត ។ នគរនោះក៏វិនាសដូចនគរមុនទៀត ។ អ្នកធ្វើសុរាទាំងពីរនាក់ រត់ចេញអំពីនគរពារាណសីទៅកាន់នគរសាកេត រត់ចេញអំពីនគរសាកេតទៅកាន់នគរសាវត្ថី ។ គ្រានោះ ព្រះចៅក្រុងសាវត្ថីទ្រង់ព្រះនាមព្រះបាទសព្វមិត្ត ព្រះអង្គទ្រង់ធ្វើសេចក្ដីសង្គ្រោះដល់អ្នកទាំងពីរនាក់នោះ ទ្រង់មានព្រះបន្ទូលសួរថា: "អ្នកទាំងឡាយត្រូវការវត្ថុអ្វីខ្លះ ? អ្នកធ្វើសុរាក្រាបបង្គំទូលថា: "ទូលព្រះបង្គំជាខ្ញុំ ត្រូវការថ្លៃគ្រឿងផ្សំ នឹងម្សៅស្រូវសាលី ហើយនឹងឃ្ទិន(១) ចំនួនប្រាំរយ" ព្រះរាជាក៏ព្រះរាជទានវត្ថុគ្រប់ តាមសេចក្ដីត្រូវការ ។ អ្នកធ្វើសុរាទាំងនោះដាក់សុរាក្នុងឃ្ទិនទាំងប្រាំរយ ហើយខ្លាចក្រែងកណ្ដុរចូល ក៏ចងឆ្មាមួយៗជិតឃ្ទិនមួយៗ ។ ឆ្មាទាំងនោះផឹកសុរាដែលហៀរចេញអំពីឃ្ទិន ហើយស្រវឹងដេកលក់អស់ទៅ ពួកកណ្ដុរមកដល់ហើយ ក៏កកេរស៊ីត្រចៀក, ច្រមុះ, ចង្កូម និងកន្ទុយឆ្មាទាំងនោះរេចអស់ហើយទៅបាត់ទៅ ។

១ បុរាណហៅថា: ពាង, ប៉ូវ, កប៉ុក សម្រាប់បិទសុរា ។

# ពិធីទ្វាទសមាស

## តាមទំនៀមព្រាហ្មណ៍នៅនគរពារាណសីប្រទេសឥណ្ឌា

## ឧកញ៉ាទេពពិទូរ ក្រសេម

(រៀបរៀងតមកនឹងចប់)

## ពិធីខែជេស្ឋ

ខែជេស្ឋ ពិធីជេស្ឋវិធានម៍ (គឺពិធីស្រង់ព្រះ) (មិនឃើញមានប្រាប់ថ្ងៃដែលធ្វើ) ព្រះមហាក្សត្រឲ្យស្រីព្រហ្មចារីតែងខ្លួន ហើយយកផ្តាំងទឹកទៅដងទឹកទន្លេគង្គា យកផ្លូងផ្កាបិទមាត់ផ្តាំងទឹក ទូលយកទៅឯវត្តប៉ាតលីជាស វត្តម៉ាដោជាស ព្រះមហាក្សត្រស្តេចទៅយកទឹកនោះស្រង់ព្រះពុទ្ធរូប ស្រង់យត្តិ ធ្វើសក្ការបូជាព្រះពុទ្ធរូបប្រគេនចង្ហាន់យត្តិ រួចហើយព្រាហ្មណ៍រំលែកយកទឹកនោះទៅស្រង់ទេវរូប ព្រះឥសូរព្រះនារាយណ៍ និងធ្វើសក្ការបូជាតាមទំនៀម ។

## ពិធីខែអាសាធ

ក្នុងខែអាសាធ ពិធីអាសាធវិធានម៍ (គឺ ពិធីហែព្រះប្រទក្សិណព្រះនគរ) នៅថ្ងៃ ៥ កើតនិមន្តព្រះពុទ្ធរូបមាស ទៅវត្តប៉ាតលីជាស វត្តម៉ាដោជាស ដាក់លើរថ មហាយត្តិឡើងគង់ក្រែស្នែង, ព្រាហ្មណ៍ពជគ្រូ

អញ្ជើញទេវរូប ព្រះឥសូរ នារាយណ៍ដាក់លើរថ ហែតាមក្រោយ ហែជុំព្រះនគរ អស់រារ ១០ ថ្ងៃ លុះគ្រប់ ១០ ថ្ងៃហើយហែចូលទៅក្នុង ព្រះរាជវាំង ព្រះមហាក្សត្រតែងគ្រឿងសក្ការបូជា ចេញទៅនមស្សការ បូជា ហើយនិមន្តយតិមកធាន់ៗ ហើយនិមន្តព្រះពុទ្ធរូប នឹងទេវរូប ប្រតិស្ឋានដូចដើម ៗ

## ពិធីក្នុងខែស្រាពណ៍

ខែស្រាពណ៍ ពិធីនាគវិធានម៌ (គឺពិធីបូជានាគរាជ) ថ្ងៃ ៥ កើត តែងគ្រឿងសក្ការបូជា នំបង្អែម ទៀនធូបផ្កា បូជានាគរាជឈ្មោះ សេសៈ ព្រាហ្មណ៍រាជគ្រូសរសេររូបសេសៈនាគរាជ ក្បាល ៨ កន្ទុយ ៨ កាលនឹងបូជានោះគេបិទទ្វាររាំងទ្វារផ្ទះគ្រប់ៗ អន្លើ ហើយនាំគ្នាបូជាទូទៅ គ្រប់ផ្ទះ ៗ

## ពិធីក្នុងខែភទ្របទ

ខែភទ្របទ ពិធីភទ្របទវិធានម៌ (គឺពិធីបុណ្យថ្វាយទឹកឃ្មុំ) ថ្ងៃ ១៥ កើតបុណ្យថ្វាយទឹកឃ្មុំ ដល់យតិនៅក្នុងព្រះរាជវាំង នឹងកល់ផ្ទះសំបែង ស្រេចហើយព្រាហ្មណ៍រាជគ្រូយកអំបោះទៅចងកន្ទាំងថ្មី ប្រគល់ឲ្យអ្នក ម្ចាស់ឆ្នាំដែលធ្វើបុណ្យទាំងនោះ យកទៅបណ្តែតក្នុងទន្លេគង្គា ហើយ

ចុះឆ្លងទឹកក្នុងទន្លេនោះ ដំរះកាយឲ្យបរិសុទ្ធស្រេចហើយ តែងខ្លួនរៀបរយមកក្រាបសំពះមាតាបិតា ។

## ពិធីក្នុងខែអស្សុជ

ខែអស្សុជ ពិធីអស្សុជវិធានម៍ (គឺពិធីប្រសិទ្ធអាវុធ) ថ្ងៃ ៩ កើត ព្រះមហាក្សត្រទ្រង់ឲ្យហោរាធ្វើពិធីដំរះអាវុធ រួចហើយតែងគ្រឿងបូជាប្រសិទ្ធិអាវុធ, ពួកដែលតាំងនៅក្នុងសីលមិនសម្លាប់សត្វ យកអាវុធនោះទៅកាប់ដើមដូងជាដើម អ្នកមិនកាន់សីល យកអាវុធនោះទៅកាប់គោក្របីលអាវុធ ហើយទាហានទៅសំដែងក្បួនអាវុធថ្វាយព្រះមហាក្សត្រទតនៅមុខព្រះរាជវាំងព្រមគ្នា, ក្នុងខណៈនោះ អ្នកស្រុកដែលមានប្រាក់មាស ក៏យកប្រាក់មាសទៅថ្វាយព្រះមហាក្សត្រតាមមានតិច-ច្រើន អ្នកគ្មានប្រាក់មាស ត្រូវយកផ្កាទៅថ្វាយ គ្រានោះព្រះមហាក្សត្រ ត្រាស់ឲ្យសេនាបតីពិចារណាមើលសេចក្ដីសុខ-ទុក្ខរបស់រាស្ត្រ, ហើយទ្រង់ត្រាស់ឲ្យប្រុងប្រៀបសេនាទាហានអ្នកចំបាំង ឲ្យមានគ្រប់គ្រាន់ព្រមទុកសម្រាប់ផែនដី ។

## ពិធីខែកត្តិក

ខែកត្តិក ពិធីកត្តិកវិធានម៍ (គឺពិធីបង្ហូតគោមថ្វាយព្រះ) ថ្ងៃ ១ កើត យកឈើវែងមកធ្វើជាដងគោម ដោតដាំក្នុងព្រះរាជស្ថាន បង្ហូតគោម

ពួកអ្នកស្រុកគ្រប់ស្រុក-ភូមិ-ផ្ទះ បង្ហូតគោមដូចគ្នានេះ បូជាអស់រយៈ ១៥ ថ្ងៃ លុះដល់ថ្ងៃ ១ រោច ធ្វើផែតូចៗ អុជប្រទីបបណ្ដែតទៅក្នុងទន្លេគង្គា ហើយអុជកាំជ្រួចបូជាព្រះនៅវត្តប៉ាតលីជាស វត្តម៉ាជោជាស រូបសម្រិតគោមចុះ ។

## ពិធីខែមិគសិរ

ខែមិគសិរ ពិធីមិគសិរវិធានម៍ (គឺពិធីបូជាទេវតារក្សានគរ) ថ្ងៃ ៥ កើតយកទង់ធំសម្រាប់ស្រុកទៅដោតនៅទីទាំង ៨ ទិសជុំវិញព្រះនគរ ហើយតែងគ្រឿងពលិការអ្នកតាម្ចាស់ស្រុក និងទេវតារក្សាព្រះនគរ, ចំនួន ១០ ថ្ងៃ លុះគ្រប់កំណត់ថ្ងៃហើយ ក្នុងថ្ងៃទី ១០ ទាហានឡើងជិះសេះ ជិះដំរីលេងដើងនៅមុខព្រះទីនាំងថ្វាយព្រះមហាក្សត្រទត បើត្រូវការធ្វើសឹកសង្គ្រាមនឹងប្រទេសណា ច្រើនតែលើកទៅក្នុងខែនេះ ។

## ពិធីខែបុស្ស

ខែបុស្ស ពិធីបុស្សវិធានម៍ (គឺពិធីបូជាព្រះគង្គា) ថ្ងៃ ១ កើត ព្រះមហាក្សត្រនឹងអាមាត្យមន្ត្រី ទៅធ្វើពិធីបូជាព្រះគង្គា ក្នុងទន្លេគង្គា ហើយអង្គុយបរិកម្មប្រលេះផ្គាំនៅមាត់ទន្លេគង្គា ១ ថ្ងៃទាល់ល្ងាច ។

## ពិធីខែមាឃ

ខែមាឃ ពិធីមាឃវិធានទ៍ (គឺពិធីយោលទោង) នៅថ្ងៃ ១៣ កើត យករូបព្រះឥសូរទៅដាក់ទោងយោលទាំងធ្វើសក្ការបូជាទេវរូបនោះ ៣ ថ្ងៃ ។

## ពិធីខែផល្គុន

ខែផល្គុន ពិធីផល្គុនវិធានទ៍ (គឺពិធីស្រោចទឹក) ថ្ងៃ ៥ កើត ព្រាហ្មណ៍រាជគ្រូចូលទៅស្រោចទឹកថ្វាយព្រះមហាក្សត្រ ព្រះអគ្គមហេសីនឹងព្រះរាជបុត្រ ព្រះរាជធីតា គ្រានោះពួកអ្នកស្រុកយកទឹកស្រោចគ្នា សាចគ្នា ទាំងយកផ្កាចោលគ្នា ដោយមិនមានប្រកាន់គ្នា ស្រេចហើយបបួលគ្នាទៅវត្ត ធ្វើសក្ការបូជាព្រះពុទ្ធរូប ទាំងនិមន្តយតិធាន់ ។

ខ — ទេពពិទូរ ។

លោកានេយ្យពាក្យកាព្យ

(តមក)

ឃើញដើមស្វាយនោះ លោលោតឡើងស្ទោះ លើចុងព្រឹក្សា
ទឹកមន្តអាគម ឧត្តមបណ្ណា សែកសិល្បសាស្ត្រា ដូចគ្រូប្រដៅ ។
ឯស្វាយផ្លែផ្កា ច្រើនឥតគណនា សន្ធោទុំខ្ចៅ ជ្រុះមកដល់ដី ទុំខ្ចី
ក្រាស់ក្រៅ មនុស្សម្នាចូលទៅ រើសបរិភោគា ។ ឯក្សត្រត្រានត្រើយ
សោយស្វាយស្រេចហើយ ប្រទានទ្រព្យា ទើបស្តេចបន្ទូល សា
ស្ទួរទៅថា ទៅចេះពីណា មន្តនេះប្រពៃ ។ ទិព្វសកុមារ ស្តាប់ព្រះ
ឧង្ការ ក្សត្រក្សាន្តដេស្ដដៃ ពុំថ្លែងដោយពិត ពុំទិត្យឡើយនៃ មុសា-
វាទក្រៃ ពុំពិតសត្យា ។ ក្រាបថ្វាយបង្គំ ទើបទូលថាខ្ញុំ ស្វះស្វែង
យាត្រា ឆ្ពោះទៅសំណាក់ ទាល់តក្កសិលា រៀនពីទិសា—បាមោក្ខ
ជាគ្រូ ។ ហេតុតែអន្ធពាល ល្មិលគុណគ្រូការ —ណោះឯងឈ្មោះក្បួ
ក្បិណនោះទេវតា បាកមុខគ្រូវ អង្គឲ្យអាស្រូវ សិល្បសាស្ត្រសូន្យសោះ ។

មានកាលមួយថ្ងៃ ស្តេចត្រេកព្រះទ័យ ប៉ុនប៉ងចំពោះ ត្រាស់
ឲ្យដប្បមន្ត ទិព្វគន់ស្ទានស្ទោះ ទិព្វសកាលណោះ ជប្បថ្វាយក្សត្រា ។
បៀមទឹកពេញមាត់ ពានឡើងដល់ថ្វាត់ លើចុងព្រឹក្សា ព្រួសចេញ
ពីមាត់ បង់បាត់ផ្លែផ្កា មន្តសាបសោះសា ឥតពំនាក់ឡើយ ។ កាល
ណោះមហាក្សត្រ បើកបន្ទូលថ្វាត់ ត្រាស់ថាចៅអើយ ពុំសំដែងមន្ត

ទំពួកទន់ព្រងើយ ខ្វះខុបៅអើយ សំងំធ្វើអ្វី ៗ បុរសស្តែងស្តាប់ អស់អាថ៌សារស័ព្ទ ព្រះបាទបក្រី ទៀងទើបគន់គិត កងចិត្តថារុំ អញនឹងស្រដីដូចម្តេចក៏ជា ៗ បើថ្លែងដោយពិត សមស្តេចគន់គិត ថាអញនេះណាកុហកលើសលន់ ពេកពន់សោះសា ខុខាសបន្ទា គួរមុសារ៉ាទ ៗ ទើបទូលទៅថា បពិត្រក្សត្រា សម្តេចនរនាថ ពីមុនស្តេចប្រើ ខ្ញុំធ្វើសង្ឃាត ត្រូវបុក្សពុំឃ្លាត បានដូចប៉ុនប៉ង ៗ ស្តេចស្តាប់ហ្នោះហើយ ពិតពុំលង់ឡើយ បន្ទូលសាសង ពីមុនព្រះស្តែង ពុំថ្លែងទំនង រកប្ញក្សពាលផង ប្រាប់អញឲ្យដឹង ៗ ក្រែងព្រះស្តែងធ្វើ ស្វាធ្យាយអំពើទីទៃផ្សេងៗ ទឹងគ្រូប្រដៅ ដោយនូវដំណើង មានបើខុសដឹង ទើបសាបមន្តនោះ ៗ ទំពួសស្តាប់ហើយ ពុំអាចធ្លាសឆ្លើយ នៅស្ងៀមស្ងួនឲ្យសោះ ស្តេចបន្ទូលទៀត ខំឈ្លៀតឆ្លើយដោះ ដោយដំណើរនោះស្តេចប្រាប្រសេចក្តី ៗ ទ្រង់ព្រះសង្វេគ ស្ងប់ស្ងៀមឯងឯក ពុំមានមេត្រីស្តេចបើកព្រះស្ងួរ បន្ទូលរឹងខ្វី ថាអាអប្រិយ អសារមន្តសោះ ៗ ព្រះអង្គទេសនា សូត្រជាគាថា សួរស័ព្ទពីពេះ ដៀលល្មិលគុណគ្រូអាស្រូវស្ងួនឲ្យសោះ បន្ទូលតែម៉្លោះ សូត្រជាគាថា ៗ

ឃរន្ធាបិ អដ្ឋសេបិ វាសិជិតា គាមសុតិ ឌុមជិតា
វនោហិតា ឱមុត្តមេ ៗ ហៃមហាជនផង នេះគឺទំនង បាលីបន្ទ

ថាឃុំធំពិត ឃុំផ្ចិតស្ថិតឯ[1] ដើមឈើជ្ញូវទេ លោកហៅឧត្តម គ្រូនាដូច ធម៌ សិល្បសាស្ត្រសម្មា អ្នកហៀនមធ្យម បើមានបេះជ្រះ ជាក់ច្បាស់ លោកសម លោកហៅឧត្តម ប្រសើរវិញណា ៗ ព្រះបាទក្សត្រថ្លៃ បន្ទូលហ្នោះនៃ ទ្រង់ព្រះក្រោធា ត្រាស់ប្រើអាមាត្យ សង្ឃាតម្មា ឲ្យចាប់ ចង្កា ល្អិលគុណគ្រូទៅ ៗ ធ្វើទុក្ខធ្វើទោស កុំឲ្យសន្តោស អាហោរកំ-ឡៅ អាមាត្យផងផាប់ ចូលចាប់នាំទៅ តាមក្សត្របមហៅ ត្រាស់លើ សិរសា ៗ ត្រាស់ហើយបង្គាប់ ថាអាគ្រូឡាប់ ទៅឯគ្រូអា សង្កាតរក រៀន របៀនសាស្ត្រា ទើបមកនគរ ប្រទេសនេះបាន ៗ រីឯអានោះ ចរះចេញទៅស្ពោះ សំដៅទៅឋាន គ្រូក្រឡេកយល់ សិស្សដល់មកស្ថាន ទៅរឺយទៅមាន បើមករកគ្រូ ៗ បុរសផិពប ទូនសំពះក្រាប ថាម្ចាស់ សិរសើ ខ្ញុំជួបមនុស្សម្នាក់ ក្នុកខ្ទាក់ដើរដី ពុំឃល់ស្មើ ថ្ងស់ធ្លាក់ក្ដនិងជ្រោះៗ សូមទានម្ចាស់ស្រង់ ស្វាធ្យាយជម្រង់ មន្តនោះសាបសោះ បណ្ដាល មាណព ដឹងត្រប់ជួហ្នោះ ថាឧអះឧះ ស្ដាយកុំប្រដៅ ៗ មានមន្តឯណា ថ្ងៃភះផ្សង់ពីគ្នា នេះអាកំឡៅ ធម៌មន្តឲ្យរៀន របៀនជ្រះជ្រៅ អ្នកពាល កំឡៅ ពុំដែលថេរបិត ៗ មួយអ្នកកាន់កាច ពោលពាក្យកំណាច មួយ អ្នកទ្រុស្តមិត្រ មួយស្រដីកួត ពុំសូត្រពាក្យពិត មួយគឺអ្នកឥត សីលសុទ្ធ សត្យា ៗ មួយល្អិលគុណគ្រូ ទាំងប្រាំនេះក្ងរ បើអ្នកឯណា បេះហោបេះ

---

១ ច្បាប់ខ្លះថា "ឃុំធំឃុំផ្ចិត បើស្ថិតឯរឯ" ។

ធមិ សព្វសិល្បសាស្ត្រ បេះមន្តក្រិត្តិកា សាបសោះឥតត្រើយ ៗ ទិព្វសរ កុមារ ស្តាប់ពាក្យអាចារ្យ ទូន្មានប្រោះហើយ ថាខ្លួនអសារ ឥតការ ឥតត្រើយ ពុំចង់រស់ទៀយ ចូលស្ទាប់ក្នុងព្រៃ ៗ មហាសត្វនាំទ-ពានថ្លែងអំពី និយាយនោះនៃ ទើបទូលព្រះមហា — ក្សត្រាជេស្ឋជ័យ នេះឯងក្សត្រថៃ្ង អ្នកល្មិលគុណគេ ៗ ទេព្តាបាក មុខមានទុក្ខា ឥត ឯល្ហើយល្ហែ មានទុក្ខនោះធ្ងន់ ពិតពុំទំនេ បទភ្លេចគុណគេ បានបាប ធ្ងន់ក្តាត់ ៗ សេនាបតី ស្តាប់ពាក្យពោធិ អៀនអាក់អន់ចិត្ត រំដួលក្នុង ថ្លើម ដង្ហើមក្តៅក្តាត់ ទូលថាបពិត្រ សម្តេចក្សត្រា ៗ ហៅធនញ្ជ័យនេះ ចិត្តធំជៀលគេ ដែលខ្ញុំករុណា អញខ្ញុំសូមកាប់ សម្លាប់ខ្លួនវ៉ា ស្តេច ស្តាប់សេនា-បតីនោះហើយ ៗ សៀមចូលទៅក្នុង ប្រាសាទរមេ-ង្គល គន់ព្រងើយ សេនាបតី ចុះពីគាល់ហើយ ខេរខឹងឥតស្បើយ ទៅ ឋានគ្រឹះហា ៗ ទិទាំនចាយថែង ចរចាថ្វាថ្លែង ពីអាជិប្រែស្ទា អ្នក ភ្លេចគុណគេ បន្ទូតាថា ស្ទូវបុត្តណីនា ដំណើរម៉េះហោង ៗ

បទពុំនោលថ្លែងទំន ពោធិច្បាស់ច្បង ប្រាំមួយដណ្តប់ផ្ទាំហើយ សេនាបតីឥតត្រើយ ខេរខឹងពុំស្បើយ កំឡើងទៅគាល់ក្សត្រា ៗ ក្រាបថ្វាយបង្គំទូលថា បពិត្រព្រះមហា- ពជអើយរីកជការផង ៗ ផ្ទៃក្រោមពីមុនមកហោង មួយអ្នកទ្រើសឃ្នង មានតានុភាពមហិមា ៗ មួយអ្នកឈ្មោសវៃអធ្យា- ស្រ័យសារបញ្ញា មួយគឺបំពោតវិលវល់ ៗ

មួយគឺលេះលោះធ្វើគល លោកថាបុគ្គល ទាំង ៤ ដំពូកនេះណា ៗ
លោកប្រើក្សត្រិយ៍អស់ក៏ នេះពុំយកជា អាមាត្យជំនិតស្មានសោះ ៗ
ឲ្យក្សត្រសម្លាប់ក៏នោះ បើពុំដូច្នោះ ឲ្យដាក់ប្រក់គាពង ៗ ដាក់គុក
ចាក់សោខ្នោះឃ្នាង ឲ្យក៏បានពង បណ្តេញចេញពីនគរ ៗ បពិត្រថ្លៃ
ក្រោមកូនរ ធនញយកូតករ កុហកព្រះបាទក្សត្រា ៗ ហើយបេះបំ-
ពោតមាយា បពិត្រក្សត្រា ស្តេចឲ្យសម្លាប់គូរគាប់ ៗ បើព្រះអង្គពុំ
សម្លាប់ សមក៏នឹងកាប់ ព្រះអង្គអម្ចាស់វិញណា ៗ ស្តេចស្តាប់សារស័ព្ទ
ក៏ថា ព្រួយព្រះចិន្តា គិតភ័យពេកពន់កន្លង ៗ ហើយបើកបន្ទូលសាសង
ច្នោះយើងប៉ុនប៉ង បំណងគំនិតគិតម្តេច ៗ បើយើងសម្លាប់ពុំស្រេច
ក៏ប្រែគិតគេច វិលមកសម្លាប់យើងវិញ ៗ ទោះយើងបំបរបណ្តេញ
ក៏ចរចាកចេញ ទៅឯប្រទេសដទៃទៀត ៗ នឹងនាំសត្រូវមកបៀត ឲ្យ
ខូចបង់ស្រៀក ឥតការអេសារសូន្យសោះ ៗ គិតគូរស្វះស្វែងមើលទោះ
មន្ទិលទោសនោះ ខុសហើយយើងធ្វើទោសបាន ៗ ធម្មតាអ្នកប្រាជ្ញ
បើមាន ទោសតាស់តាលប្រាណ សឹងជឹងកំហុសអាត្មា ៗ ហេតុនោះ
អស់យើងគ្រប់គ្នា ស្វះស្វែងទោសក៏ ឲ្យបានលុះកណ្តាប់ដៃ ៗ សេនា-
បតីអរក្រៃ ក្រោះលាវិលវៃ មកដល់មណ្ឌលអាត្មា ៗ ចាប់ដើមពីនោះ
ក្សត្រា អាមាត្យសេនា- បតីឃុំទោសមហាសត្វ ៗ លោកថាបើ
ស្រឡាញ់បាត់ ឆ្នាំគ្នងខុសមាត់ ប៉ុន្មានសឹងជាគាប់វិញ ៗ បើស្អប់

វែនមិនស្រឡាញ់ ផ្គាប់ប៉ុន្មានវិញ សឹងជាប្រែខុសវិញស្មោះ ៗ ពោ-
ធិសត្វសោកដឹងប្លោះ ពិតពិទោសនោះ អ្នកមិនស្រដីឡើយហោង ៗ
ទោះអ្នកឡើងគាល់ម្តងៗ អស់នរអ្នកផង សំងំពុំហានចរចា ៗ ពុំយល់
កំហុសទោសា ប្រាំពីរទិវា រីឯអស់រាជបណ្ឌិត ៗ ទាំងបីមិញប្រែភ័យកិត
ប្រយ័ត្នគំនិត ខ្លាចខុសឯខ្លួនឯងវិញ ៗ មានកាលមួយថ្ងៃស្តេចចេញ ផ្លូ
ពេញធំមិញ សេនាមន្ត្រីបរិពារ ៗ គង់គាល់អនេកជាសជា -ជួបជួន
អាចារ្យ ទាំង ៤ ឡើងគាល់ក្សត្រា ៗ ស្តេចថប់បទសៀមគ្រប់គ្នា បើក
បន្ទូលថា អាចារ្យម្តេចមិនស្រដី ៗ ម្តាយបង្កើតព្រះស្តេងពី មុនមកបទអ្វី
ឲ្យរៀនច្បាប់សៀមប្តូរម្តេច ៗ បណ្ឌិតទាំងបីយល់សេច- ក្តីច្បាប់ជាកិច្ច
ទូលឲ្យតែរូបអាត្មា ៗ សុន្ទរព័យទូលថា បពិត្រក្សត្រា ខ្ញុំចេះច្បាប់មួយ
ផ្សំថ្នាំ ៗ ឈ្មោះបញ្ចប័ត្រឈើទាំងប្រាំ យកស្លឹកផ្សំថ្នាំ ឲ្យមានអាយុយឺន
ក្រៃ ៗ គឺស្លឹករលួសមួយនៃ ស្លឹកញោវិស័យ មួយស្លឹកកន្ទ្រីស្លឹកស្តៅ ៗ
ស្លឹកកញ្ឆារបុកដូចម្សៅ ទាំងប្រាំនេះហៅ ថ្នាំពិសេសសុទ្ធគ្នាត់ណា ៗ ឲ្យ
សូទ្យធ្វើជាគុលិកា លេបសព្វទិវា ប្រែជាអាយុវែងវិញ ៗ រីច្បាប់ខ្ញុំឯងនេះ
មិញ ដូចអ្នកស្រឡាញ់ បាបុបាយឲ្យអាយុមាន ៗ ស្តេចស្តាប់ដណ្តឹង
ទៅថ្កាន ឥដ្ឋារម្មណ៍មាន ច្បាប់នោះដូចម្តេចព្រះស្តេង ៗ ឥដ្ឋារម្មណ៍
បន្ទូលថ្លែង បពិត្រខ្ញុំឯង ខ្ញុំចេះច្បាប់ដេកវិញណា ៗ បើប្រែក្បាលទៅ
បូព៌ា នូវមានប្រាជ្ញា ក្រៃលែងអ្នកផងទាំងឡាយ ៗ បែរទៅទិស

ទក្សិណសាយ អាយុវែងឆ្ងាយ បើប្រែទៅទិសឯលិច ៗ កើតទុក្ខក្តៅ
បិត្តបត្តិច អពមង្គលកិច្ច កើតទុក្ខអង្គអនាទរ ៗ ទោះប្រែក្បាលទៅ
ឧត្តរ ទៀងតែនឹងមរណ៍ ស្លាប់ឆាប់ប្រាកដពុំលែង ៗ ទើបស្តេចបើក
បន្ទូលថ្លែង ថាអក្ក័យឯង ព្រះស្តែងតើបេះបញ្ជាប់អ្វី ៗ អក្ក័យបណ្ឌិត
ទូលទី ខ្ញុំបេះបញ្ជាប់ទី- បាយហើយក៏ដេកនឹងឆាត់ ៗ ហូបបាយហើយ
ដោះទៀងថ្វាត់ កំឡាំងច្រើនក្កាត់ ឥតអ្នកឯណាស្មើឡើយ ៗ ហូបបាយ
ដើរចង្ក្រមហើយ ប្រសើរជាត្រើយ នឹងមានអាយុវែងក្រៃ ៗ ហូបបាយ
ហើយតេវិលវៃ អ្នកនោះឯងនៃ នឹងស្លាប់ឆាប់ក្រៃក្កាត់ណា ៗ មួយសោត
ដូចដេកវិញជា ប្រែទៅបូពា៌ នឹងមានអាយុយឺនក្រៃ ៗ ប្រែទៅឯត្បូង
នោះនៃ មានទ្រព្យប្រែវិត ប្រែទៅឯលិចនោះណា ៗ នឹងមានកិត្តិយស
សក្កា ប្រែទៅឧត្តរ នឹងស្លាប់វិនាសឥតត្រើយ ៗ ស្តេចស្តាប់សារស័ព្ទ
ហ្នោះហើយ ពិតពុំលង់ឡើយ ថាធនញ្ជ័យតើបេះម្តេច ៗ កាលណោះព្រះ
ពង្សពោធិ-សត្វសាងបារមី ពន្លកពង្សពុទ្ធសាស្តា ៗ គន់គិតក្នុងចិត្ត
ឯងថា អញយកគម្ពា ទូន្មានសឹងថាជាខុស ៗ អស់នេះសឹងឥតសប្បុរស
ត្រូវថាជាខុស ខុសហើយយកមកថាត្រូវ ៗ ទូលថាបពិត្រព្រះកូ-បាល
ខ្ញុំឥឡូវ បេះបញ្ជាប់ប្រាំពីរប្រការ ៗ ស្តេចស្តាប់ហើយព្រះកូបាល ត្រាស់
ថាអាចារ្យ បញ្ជាប់នោះតើហេតុដូចម្តេច ៗ ទៅថ្លែងសំដែងសេចត្រេច
ឲ្យដឹងគលគិច្ច ដំណាំងដំណើរនោះណា ៗ ពោធិសត្វក្រាបទូលថា

បពិត្រធម្មតា ស្រីក្រមុំទាំងឡាយ ៗ បើមានអ្នកសហាយ ស្អប់ខ្ពើ
ណាយ នៅថ្ងៃសីលជិនណាសំណា ៗ ចង់តែលង់ឥតសន្សា នោះឯង
ថាជា ប្រសើរឯស្រីអប្បលក្ខណ៍ ៗ រីអ្នកកំឡាចស្អប់អ្នក ពាហាន
សិទ្ធិស័ក្តិ មួយគឺអ្នកខ្សត់នោះណា ៗ ស្អប់នៃអ្នកមានទ្រព្យា មួយ
ខ្ញៅពាលា ស្អប់នៃអ្នកមានប្រាជ្ញប្រាយ ៗ មួយអ្នកទុជនទាំងឡាយ
សីលស្អប់ជិនណាយ នៃអ្នកសប្បុរសប្រពៃ ៗ មួយគឺអាមាត្យក្សត្រថ្ងៃ
ជ្រោមស្អប់ជិននៃ អ្នកគាប់ទង់ម្ចាស់សិរសា ៗ នេះហៅវត្តប្រាំពីរ
ប្រា- ការគួរក្សត្រា ស្តេចជ្រាបដំណើរសេចក្តី ៗ កាលណោះសេ-
នាបតី ស្តាប់ពាក្យពោធិ-សត្វហើយក៏ត្រេកត្រោធក្រៃ ៗ ខាំមាត់
ហើយលាត់ទាំងដៃ- អារទើបថាហៃ ធនញ្ជ័យម្តេចថាដូច្នោះ ៗ ចៅ
ថាយើងស្អប់ចៅនោះ បទចៅចេះដោះ ចេះផ្គាប់ព្រះបាទក្សត្រា ៗ
ថាយើងជ្រោមស្អប់គ្រប់គ្នា ចៅឯងចៅជា អ្នកសប្បុរសប្រពៃ ៗ
ចៅផ្គាប់ត្រូវព្រះហឫទ័យ អស់យើងសព្វថ្ងៃ ចៅថាយើងស្អប់ចៅណា ៗ
ពោធិស្តាប់ហើយឆ្លើយថា ឱអ្នកសេនា-បតីអើយពាក្យអញនេះ ៗ អញ
ពុំស្រដីបទចេះ ពើយរកកលរះ អាស្រ័យដោយយោបល់ថ្លែង ៗ
ឱសេនាបតីឯង ជាអ្នកវង្វេង ទទួចបង់ឈ្មោះពិតណា ៗ ព្រះបន្ទូល
ជាធម៌ថា ឥតសប្បុរសក៏ យល់គេមានទុក្ខអរក្រៃ ៗ មួយបើយល់គេ
មានភ័យ បង់ទ្រព្យទ្រៃ ក៏អរឥតឯឧបមា ៗ មួយបើយល់គេឈ្មោះគ្នា

អវេងសោះសា ហេតុចិត្តអន្ធពាលពេកក្រៃ ។ អ្នកកាចវុជិនចង្រៃ
មានឈ្មោះមួយថ្ងៃ សង្រៃសង្រែងចិន្តា ។ អ្នកកាចដូចបន្ទា ត្រូវត្រង់
បាទា រាំមុតចេញឈាមសស្រាក់ ។ បើការបន្ទាឲ្យពាក់ ស្បែកជើងដើរ
ជាក់ ជាន់លើឲ្យល្អិតសូន្យសោះ ។ អ្នកកាចចិត្តចង់ស្មានស្មោះ ពិឃាដ
គេនោះ ស្មានជីវិតឯងវែងក្រៃ ។ រស់បានមួយពាន់ឆ្នាំទៃ ពុំដឹងនឹងក្ស័យ
នឹងធ្លាក់ទៅឋានអវិចី ។ បើការអ្នកកាចអប្រិយ លោកឲ្យបៀតពី
បំផ្លាយឲ្យធ្លាយឲ្យធ្លាប់ ។ សេនាបតីស្ដែងស្ដាប់ អស់គាថិសារស័ព្ទ
រំងខ្លាចអំណាចអ្នកហោង ។ ពុំហានស្រដីសាសង នៅស្ងៀមជាម្ដង
អង្គុយពត្ទិះសោះសា ។ កាលណោះឯមហាក្សត្រា ភិតភ័យតក្កមា
ក៏ចូលទៅក្នុងប្រាសាទ ។ មាសម័យសន្ទៅស្អាងស្អាត ត្រិះរិះសង្វាត
មើលមហាបុរសសេង្ហា ។ បសំសាទិបញ្ញា វនិដ្ឋតោ វប្រស្នា
ច្បាប់ចប់ម៉េះហោង ។

(មានត)

# ប្រវត្តិពួកឧបាសិកា

**វិសាខា-មិគារមាតា** — ជាអ្នកស្រុកភទ្ទិយៈនៅដែនអង្គៈ ជាកូនធនញ្ជ័យសេដ្ឋី ទំងនាងសុមនទេវី ត្រូវជាចៅរបស់មេណ្ឌកសេដ្ឋី ។ លុះនាងវិសាខា មានអាយុបាន ៧ ឆ្នាំ ព្រះបរមសាស្តាស្តេចទៅនគរនោះ វេលានោះមេណ្ឌកសេដ្ឋី បានដឹងដំណឹងថា ព្រះទសពលស្តេចមកដល់ស្រុករបស់ខ្លួន ទើបផ្តាំឲ្យនាងវិសាខាទៅទទួលព្រះអង្គ ។ សម្តេចព្រះបរមសាស្តាទ្រង់ទេសនាប្រោស នាងបានសម្រេចសោតាបត្តិផល កាលស្តេចចូលទៅដល់ស្រុកភទ្ទិយៈហើយ មេណ្ឌកសេដ្ឋីក៏ចូលទៅគាល់ បានស្តាប់ព្រះធម្មទេសនាបានសម្រេចសោតាបត្តិផលដែរ លោកធ្វើទានយ៉ាងធំថ្វាយព្រះអង្គជាវេលាកន្លះខែ ឯព្រះបរមសាស្តា ស្តេចប្រថាប់លមសមគួរនឹងពុទ្ធអធ្យាស្រ័យហើយក៏ស្តេចចៀសចេញទៅ ។

ឯព្រះបាទកោសលរាជនៃក្រុងសាវត្ថី បានចាត់ផ្ញើព្រះរាជសារទៅថ្វាយព្រះបាទពិម្ពិសារ មានសេចក្តីថា សេដ្ឋីដែលមានទ្រព្យសម្បត្តិរាប់ប្រមាណមិនបាន ក្នុងស្រុករបស់ទូលបង្គំជាខ្ញុំឯណោះមិនមានឡើយ តែក្នុងស្រុករបស់ទ្រង់មានច្រើន ដូច្នេះសូមទ្រង់ប្រទានត្រកូលសេដ្ឋីទៅឲ្យទូលបង្គំជាខ្ញុំខ្លះផង ។ ឯព្រះបាទពិម្ពិសារ កាលបានទទួលព្រះរាជសារក៏ទ្រង់ប្រឹក្សានឹងពួកអាមាត្យរាជបរិពារសេដ្ឋីគហបតីទាំងពួង ទើបផ្តុំសម្រេចថា ត្រូវបញ្ជូនធនញ្ជ័យសេដ្ឋី ជាបុត្ររបស់មេណ្ឌកសេដ្ឋីឲ្យទៅ

ទើបឲ្យធ្វើព្រះរាជសារតបទៅព្រះបាទកោសលរាជ ព្រះបាទកោសលរាជក៏មានព្រះទ័យត្រេកអរ ហើយទ្រង់ព្រះរាជទានស្រុកសាកេត មានចំងាយពីស្រុកសាវត្ថី ៧ យោជន៍ដល់ធនញ្ជ័យសេដ្ឋី ។

នៅក្រុងសាវត្ថី មានបុត្ររបស់មិគារសេដ្ឋីម្នាក់ឈ្មោះបុណ្ណវឌ្ឍនកុមារ លុះចំរើនវ័យឡើង បិតាគិតរកភរិយាឲ្យសម្រាប់ជាគូគ្រងតាមទំនៀមយកកាស ហើយឲ្យស្ទុះស្វែងរកកូនប្រសារហូតទៅដល់ស្រុកសាកេត ពេញចិត្តនឹងនាងវិសាខា ជាធីតារបស់ធនញ្ជ័យសេដ្ឋីទើបគាត់ចែងជណ្ដឹងតាមរបៀប លុះព្រមព្រៀងគ្នាហើយ ទើបគាត់ចែងរៀបមង្គលការ នៅស្រុកសាកេតនោះ ។ ការរៀបមង្គលការគ្រានោះ រៀបចំធ្វើយ៉ាងអឹកធឹកមហោឡារ ព្រះបាទបសេនទិកោសល ស្តេចយាងទៅជាអធិបតីក្នុងមង្គលការនោះដែរ ។ ធនញ្ជ័យសេដ្ឋីបានរៀបចំទទួលទ្រង់សមព្រះកិត្តិយសគ្រប់ប្រការ មុននឹងបញ្ជូននាងវិសាខាទៅកាន់ត្រកូលស្វាមី បានឲ្យឱវាទ ១០ ខ មានសេចក្តីថា :

១. ភ្លើងខាងក្នុងកុំនាំចេញ ។

២. ភ្លើងខាងក្រៅកុំនាំចូល ។

៣. កាលបើគេឲ្យតោងឲ្យតប ។

៤. កាលបើគេមិនឲ្យកុំឲ្យ ។

៥. កាលបើគេឲ្យក៏ដោយ មិនឲ្យក៏ដោយតោងតែឲ្យ ។

៦. គប្បីអង្គុយឲ្យស្រួលបួល ។

៧. គប្បីបរិភោគឲ្យស្រួលបួល ។

៨. គប្បីដេកឲ្យស្រួលបួល ។

៩. គប្បីបំរើភ្លើង ។

១០. គប្បីសំពះទេវតាខាងក្នុងផ្ទះ ។

ឱវាទ ១០ ខនេះមិគារសេដ្ឋី អែបស្ដាប់បានឮដែរ លុះព្រឹកឡើង លោកធនញ្ជ័យសេដ្ឋីឲ្យប្រជុំពួកពលបរិវាររួចតាំងកុដុម្ពី ៨នាក់ទុកសម្រាប់ជំនុំជម្រះទោសានុទោសរបស់ធីតា លុះធ្វើមង្គលពិធីរួចស្រេចហើយ ទើបបញ្ជូនធីតាទៅកាន់ត្រកូលរបស់ប្ដីព្រមទាំងភោគសម្បត្តិ និងបរិវារប្រុសស្រីជាចំនួនច្រើន ។ ឯនាងវិសាខាបានប្រដាប់ដោយគ្រឿងប្រដាប់ហៅថាមហាលតាប្រសាធន៍ ដែលមានដំឡៃដល់៩កោដិ ។ នាងវិសាខាទៅកាន់ត្រកូលស្វាមីគ្រានោះ មហាជនអ្នកក្រុងសាវត្ថីមានសេចក្ដីបីតិត្រេកអរណាស់ ឯនាងវិសាខាក៏បានធ្វើបដិសណ្ឋារៈ នឹងមហាជនដោយកិរិយាសុភាពទន់ភ្លន់ ហើយឲ្យបណ្ណាការតបដល់អ្នកដែលនាំបណ្ណាការមកជូនទាំងប៉ុន្មានរៀបរយគ្រប់ប្រការ ។

កន្លងយប់នោះ មេលាបានសម្រាលកូនមកជាសេះអាជានេយ្យ ទើបនាងវិសាខានាំទាសីចុះទៅជួយកងការសម្រាលកូនមេលានឹងកូនរបស់វានោះ ។

ឯលោកមិគារសេដ្ឋី ជាពួកមិច្ឆាទិដ្ឋិ លុះរៀបមង្គលការហើយ ត្រឡប់មកដល់ក្រុងសាវត្ថី កន្លងទៅបាន ៧ ថ្ងៃ ក៏ចាត់ចែងនិមន្តសមណៈអាក្រាតជាច្រើនមកធ្វើភត្តកិច្ចក្នុងផ្ទះ ហើយឲ្យហៅនាងវិសាខាជាកូនប្រសាមកសំពះស្តួរ ៗ នាងវិសាខាបានមកឃើញ ក៏មិនមានសេចក្តីជ្រះថ្លា ហើយត្មះតិះដៀលថាជាមនុស្សមិនមានហិរិឱត្តប្បៈ មិនមែនជាសមណៈទេ ចុះបិតាឲ្យហៅខ្ញុំមកធ្វើអ្វី ហើយនាងក៏ត្រឡប់ទៅវិញ ៗ ពួកសមណៈអាក្រាតបានឃើញដូច្នោះ ក៏នាំគ្នាត្មះតិះដៀលជាច្រើន ហើយណែនាំពន្យល់ឲ្យសេដ្ឋីបណ្តេញកូនប្រសាកាឡកណ្ណីនោះចេញទៅ ៗ ឯមិគារសេដ្ឋីមិននិយាយថាអ្វីគ្រាន់តែនៅស្ងៀម ហើយបញ្ជូនសមណៈអាក្រាតអស់នោះឲ្យត្រឡប់ទៅវិញ កាលសេដ្ឋីបរិភោគអាហារដោយខ្លួនឯង នាងវិសាខាក៏ចាត់ចែងបំរើដោយល្អ ៗ

ខណៈនោះ មានព្រះថេរមួយអង្គដើរបិណ្ឌបាតមកឈរនៅមាត់ទ្វារផ្ទះរបស់សេដ្ឋី ៗ នាងវិសាខាបានឃើញគិតថា អញមិនគួរជំពបឪពុកក្មេកទេហើយថយទៅបន្តិច ដើម្បីឲ្យសេដ្ឋីបានឃើញ ៗ មិគារសេដ្ឋីបានឃើញហើយ ធ្វើព្រងើយ ហើយធ្វើជាឈ្ងោតបរិភោគអាហារទៅ នាងវិសាខាឃើញថា លោកនៅរង់ចាំយូរពេកទើបពោលទៅនឹងព្រះថេរៈថា និមន្តប្រោសសត្វទៅខាងមុខចុះលោកម្ចាស់ ឪពុកក្មេកខ្ញុំករុណាលោកបរិភោគតែបុណ្យចាស់ទេ ៗ

លុះបានឮពាក្យនោះ មិគារសេដ្ឋីក៏លោសដៃលែងបរិភោគអាហារ ភ្លាម ហើយបញ្ជាឲ្យបណ្ដេញនាងវិសាខាឲ្យចុះចេញពីផ្ទះ ព្រោះសេដ្ឋីបានទំអត់សង្កត់ចិត្តមិននិយាយស្ដី តាំងអំពីគ្រាដែលពួកទិគម្ពរយល់ទាស់មកម្ដងហើយ តែម្ដងនេះទំអត់សង្កត់ចិត្តទៅទៀតពុំបាន ទើបសេដ្ឋីចោទទោសនាងវិសាខាថា នាងពោលពាក្យដៀមដាមថាខ្លួនស៊ីអសុចិ ជាការមើលងាយប្រមាថយ៉ាងខ្លាំង ៗ តែពួកខ្ញុំម្នាក់នៅផ្ទះនោះ គ្មាននរណាហ៊ានធ្វើតាមបង្គាប់សេដ្ឋីឡើយ ឯនាងវិសាខាដដែលតវ៉ាថា បើដូច្នោះឲ្យហៅកុដុម្ពីទាំង ៨ នាក់ដែលបិតានាងបានតាំងមកឲ្យមើលការខុសត្រូវ ៗ លុះមិគារសេដ្ឋីបានអញ្ជើញកុដុម្ពីទាំង ៨ នាក់មកហើយ ទើបប្ដឹងដល់ក្រុមជំនុំជាទដំបូងថា នាងវិសាខាបានជេរខ្លួនថាជាអ្នកស៊ីអសុចិ ៗ នាងវិសាខាបានដោះស្រាយថា ថ្ងៃដែលកើតរឿងនោះ នាងកំពុងឈប់លៀងសេដ្ឋីស្រាប់តែមានភិក្ខុមួយអង្គ ដើរបិណ្ឌបាតចូលមកឈរនៅមុខផ្ទះនឹងដំពបសេដ្ឋីក៏ទទីកក្រែងចិត្ត ដើបថយចេញទៅបន្ទិចដើម្បីឲ្យលោកបានឃើញ លោកបានឃើញហើយត្រឡប់ជាធ្វើព្រងើយក្រែងលោករង់ចាំយូរពេកទើបពោលទៅថា សូមលោកម្ចាស់និមន្តទៅប្រោសសត្វខាងមុខ បិតាក្មេករបស់ខ្ញុំករុណាលោកពិសាតែបុណ្យចាស់ទេ ឯពាក្យថាបុណ្យចាស់នេះ មានសេចក្ដីអធិប្បាយថា លោកឪពុក

បានធ្វើបុណ្យទុកពីជាតិមុន ទើបបានធ្វើជាសេដ្ឋីក្នុងជាតិនេះ លោកបរិភោគតែទ្រព្យសម្បត្តិ ដែលធ្វើទុកពីជាតិមុនប៉ុណ្ណោះ ក្នុងជាតិនេះលោកមិនសន្សំធ្វើទុកតទៅទៀតទេ ។

កុដុម្ពីទាំង ៨ នាក់គាត់សេចក្ដីថា នាងវិសាខាមិនមានខុសៗ ឯមិគារសេដ្ឋីបានចោទទោស ១ពីរតទៅទៀតថា កាលដែលថ្ងៃមកដល់នោះ នាងវិសាខាមិនរវល់នឹងកូនរបស់ខ្លួនទេ ចេះតែទៅណាមកណា តាមទំនើងចិត្ត ។

នាងវិសាខាពោលដោះស្រាយថា ក្នុងថ្ងៃដែលមកដល់នោះវេលាយប់ មេលាសម្រាលកូនសេះអាជានេយ្យ ខ្ញុំបានចុះទៅជួយព្យាបាលឲ្យវាសម្រាលបានដោយស្រួល ទាំងវេលានោះក៏មានពួកទាសីជាច្រើននាក់តាមកេមទៅជួយជាមួយផង នឹងថាខ្ញុំចុះទៅដោយទំនើងចិត្តតែម្នាក់ឯងដូចម្ដេចបាន ។

មិគារសេដ្ឋីក៏ពោលលើកទោសតទៅទៀតថា កាលនាងត្រឡប់មកនោះ លោកធនញ្ជយសេដ្ឋី បានឲ្យឪវាទ ១០ ខមានសេចក្ដីដូច្នេះ ខ ១ ថាភ្លើងខាងក្នុងកុំឲ្យនាំចេញ គឺថាគ្រាន់តែភ្លើង មិនព្រមឲ្យអ្នកផ្ទះជិតខាងខ្ញុំមិនអាចធ្វើដូច្នោះបានទេ ។ ខ ២ ថាភ្លើងខាងក្រៅកុំឲ្យនាំចូលមក គឺថាបើភ្លើងក្នុងផ្ទះរលត់ មិនព្រមឲ្យយកភ្លើងក្រៅផ្ទះមកប្រើទេឬ ? ។

នាងវិសាខាកែថា ទី ១ ដែលថា ភ្លើងក្នុងកុំនាំចេញ ភ្លើងក្នុងទីនេះ សំដៅយកមនុស្សខាងក្នុងផ្ទះ រាប់តាំងអំពីឪពុកក្មេកម្តាយក្មេកនឹងស្វាមីជាដើម ព្រោះជាមនុស្សដែលគួរគោរពកោតក្រែងទុកដូចជាភ្លើង បើអ្នកអស់នេះនិយាយការសម្ងាត់អ្វីមួយ មិនត្រូវស្រីជាកូនប្រសានាំយកចេញទៅផ្សាយខាងក្រៅផ្ទះទេ ៗ ទី ២ ដែលថាភ្លើងក្រៅកុំនាំចូលនោះ គឺសំដៅដល់រឿងដែលអ្នកក្រៅផ្ទះនិយាយគ្នា មានពាក្យនិន្ទាចាក់ដោតមនុស្សខាងក្នុងផ្ទះជាដើម ស្រីជាកូនប្រសាមិនត្រូវនាំចូលមកផ្សាយខាងក្នុងផ្ទះទេ នាំឲ្យកើតជំលោះទាស់ទែងគ្នាឥតប្រយោជន៍ ៗ តអំពីនេះទៅជាសេចក្តីដោះស្រាយរបស់នាងវិសាខា ក្នុងខតទៅជាលំដាប់ ៗ

១៣– ថាកាលបើគេឲ្យសឹមឲ្យតប គឺថាបើអ្នកណាខ្ចីរបស់យើង ហើយគេយកមកសងយើងវិញ ដល់គេមកខ្ចីទៀត យើងតោងឲ្យទៀតដែរ ៗ

១៤– ថាកាលបើគេមិនឲ្យកុំឲ្យ គឺបើគេខ្ចីរបស់យើងគេមិនយកមកសងយើងវិញ ដល់មកខ្ចីក្រោយទៀតកុំឲ្យ ៗ

១៥– ថាកាលបើគេឲ្យក៏ដោយ មិនឲ្យក៏ដោយ យើងត្រូវតែឲ្យ គឺញាតិមិត្តអ្នកទីទាល់ក្រមកដល់ គេមិនអាចឲ្យអ្វីមកយើងទេ យើងគួរជួយទំនុកបំរុង ឲ្យរបស់ផ្សេង ៗ ទៅគេចុះ ដល់គ្រាក្រោយ គេឲ្យក្តីមិនឲ្យក្តី មិនបាច់ទារគ្នាទេ ៗ

១ ៦- គប្បីអង្គុយជាសុខ គឺកាលបើឃើញឪពុកក្មេកក្តី ម្តាយក្មេកក្តី ប្តីក្តី គប្បីអង្គុយក្នុងទីដ៏សមគួរ បើត្រូវក្រោកទទួលក៏តោងក្រោកទទួល មិនត្រូវអង្គុយធ្វើព្រងើយទេ ។

១ ៧- ជាគប្បីបរិភោគជាសុខ គឺមិនត្រូវបរិភោគអាហារមុនឪពុកក្មេក ម្តាយក្មេក និងប្តីទេ ត្រូវជប់លៀងលោកអស់នេះឲ្យរួចសិន សឹមបរិភោគខ្លួនឯងជាខាងក្រោយ ។

១ ៨- ជាគប្បីដេកជាសុខ គឺកូនប្រសាមិនត្រូវចូលដេកមុនឪពុកក្មេក ម្តាយក្មេក និងប្តីទេ តោងចាត់ចែងការងារឲ្យរួចស្រេច សឹមចូលដេកជាក្រោយ ។

១ ៩- ជាគប្បីបំរើភ្លើង គឺគប្បីសំគាល់ឪពុកក្មេក ម្តាយក្មេក និងប្តី ទុកដូចជាគងភ្លើង ឬស្តេចនាគរាជ កូនប្រសាស្រីត្រូវគោរពកោតក្រែងឲ្យច្រើន ។

១ ១០- ជាគប្បីឱនលំទោន ដល់ទេវតាខាងក្នុង គឺកូនប្រសាស្រីគប្បីសំពះ សំដែងសេចក្តីគោរពចំពោះឪពុកក្មេកម្តាយក្មេក និងប្តី ដែលទុកដូចជាទេវតានៅក្នុងផ្ទះខ្លួនឯង ។

កុដុម្ពីទាំង ៨ នាក់ជំនុំជំរះកាត់ឲ្យនាងវិសាខារួចពីពាក្យចោទគ្រប់ប្រការ នៅទីបំផុត សេដ្ឋីបានសូមខមាទោសនាងវិសាខា តែនាងថ្លែងសេចក្តីថា នាងក៏ព្រមទទួលខមាលុះត្រាតែសេដ្ឋីអនុញ្ញាត ឲ្យនាងធ្វើ

បុណ្យកុសលតាមសទ្ធារបស់ខ្លួន ៗ មិគារសេដ្ឋីក៏ព្រមអនុញ្ញាត តមកនាងវិសាខាបានក្រាបទូលនិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រមុខ ដើម្បីទទួលបិណ្ឌបាតក្នុងផ្ទះរបស់ខ្លួន នៅឱកាសបុណ្យនេះ នាងវិសាខាបានអញ្ជើញមិគារសេដ្ឋី ឲ្យមកស្ដាប់ព្រះធម្មទេសនាផង ៗ ដំបូង លោកមិគារសេដ្ឋីសំដែងកិរិយារឹងរុះដល់ព្រះបរមសាស្ដា តែដោយសេចក្ដីក្រែងចិត្តកូនប្រសា ទើបមកតាំងបង្ខំ ហើយអង្គុយអែបស្ដាប់ធម៌ ពីខាងក្រៅរាំងនន ៗ សម្ដេចព្រះបរមសាស្ដា ទ្រង់ជ្រាបហេតុការណ៍នោះទាំងអស់ ទើបទ្រង់សំដែងធម៌ដម្រូវឧបនិស្ស័យវាសនារបស់សេដ្ឋី នៅទីបំផុតព្រះធម៌ទេសនា មិគារសេដ្ឋីបានសម្រេចសោតាបត្តិផល ទើបញែករាំងននចេញក្រៅ ហើយថ្វាយបង្គំព្រះបរមសាស្ដា ហើយពោលទៅនឹងកូនប្រសាថា តាំងអំពីថ្ងៃនេះជាដើមទៅ ឪពុកនឹងតាំងកូនជាម្ដាយរបស់ឪពុកវិញ តអំពីនោះមកនាងវិសាខា ទើបមានឈ្មោះជាប់ថែមឡើងទៀតថា "វិសាខា-មិគារមាតា" ប្រែថា នាងវិសាខាជាមាតារបស់មិគារសេដ្ឋី ៗ

ក្នុងសម័យថ្ងៃមួយ នាងបានទៅស្ដាប់ព្រះធម្មទេសនាក្នុងព្រះជេតវនមហាវិហារ លុះវេលាត្រឡប់មកផ្ទះវិញ ស្រាប់តែពួកទាសីភ្លេចមហាលតាប្រសាធន៍ ក្រោយមកទើបរលឹកឃើញ ទើបជំរាបនាងវិសាខា ហើយត្រឡប់ទៅយកមកតែនាងលែងប្រើប្រាស់ទៀតហើយ គិតជាថ្លៃ

មហាលតាប្រសាធន៍ ហើយយកប្រាក់ដំឡៃនេះកសាងវិហារមួយឈ្មោះ បុព្វារាម ថ្វាយព្រះបរមសាស្តា ។

នាងវិសាខាមហាឧបាសិកានេះ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួនបរិច្ចាគទានធ្វើការកុសលជានិច្ច អាស្រ័យហេតុនេះ ទើបទ្រង់តាំងក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងស្ត្រីជាទាយិកាទាំងឡាយ ។

នាងវិសាខានេះតាមប្រវត្តិពោលថា បរិបូណ៌ដោយកូនប្រុស-ស្រីច្រើនណាស់ សុទ្ធតែឥតជម្ងឺឈឺថ្កាត់ មានចំនួនដល់ ២០ នាក់ ជាកូនប្រុស ១០ ស្រី ១០ ហើយកូនអស់នោះ មានជាកូនតូនជាចៅម្នាក់ ២០ ៗ តទៅទៀត ទើបលោកសន្មតថា ជាមង្គលដ៏ឧត្តមហើយមានវ័យល្អតាំងពីក្រមុំរហូតដល់ចាស់ជរា នាងមានអាយុសង្ខារដល់ ១២០ ឆ្នាំ ទើបអនិច្ចធម្ម ។

ចប់ប្រវត្តិសង្ខេប របស់នាងវិសាខាមហាឧបាសិកាតែប៉ុណ្ណេះ ។

# រឿងអាមាត្យរក្សាល្ពៅព្រះរាជទ្រព្យ

មាននិទានមួយដំណាលថា មានអាមាត្យម្នាក់តែងរក្សា និងរាប់ផ្លែល្ពៅព្រះរាជទ្រព្យរបស់ព្រះមហាក្សត្រមួយព្រះអង្គ កាលណាផ្លែល្ពៅនោះទុំក៏បេះយកទៅថ្វាយជានិច្ចពុំដែលខាន ៗ មានគាប់ជួនថ្ងៃមួយនោះ បុរសម្នាក់កាន់ទំពក់ទៅបេះផ្លែល្ពៅ ដើរទៅក្បែរខាងដើមល្ពៅ ដែលអាមាត្យនៅចាំថែរក្សានោះ ៗ អាមាត្យមើលទៅឃើញបុរសកាន់ទំពក់ថ្ពក់ផ្លែល្ពៅដូច្នោះ ទើបចេញទៅត្រួត រាប់ផ្លែល្ពៅនៅដើមនោះ ស្រាប់តែឃើញនៅតែទងទទេ ទើបគិតថាសមអាលីទំពក់ថ្ពក់ផ្លែល្ពៅទៅអម្បាញ់មិញនេះឯងជាចោរលួចហើយ អាមាត្យក៏រត់ទៅតាមចៅនោះឃើញមានផ្លែល្ពៅនៅថ្ពក់ទំពក់នៅដៃ អាមាត្យក៏ចាប់កោះនាំទៅប្តឹងចៅក្រម ថាចៅនេះឯងជាចោរលួចផ្លែល្ពៅព្រះរាជទ្រព្យ ខ្ញុំចាប់បានផ្លែល្ពៅនៅថ្ពក់ទំពក់នៅដៃ ៗ

ទើបចៅក្រមដណ្តឹងសួរថា ចៅឯងជាចោរលួចបេះផ្លែល្ពៅព្រះរាជទ្រព្យមែនឬទេ ៗ ចៅនោះឆ្លើយថាខ្ញុំមិនមែនជាចោរលួចទេ ឯផ្លែល្ពៅនោះខ្ញុំបាទបេះមកពីព្រៃដទៃទៀតទេ ៗ ទើបចៅក្រមនាំសេចក្តីនោះក្រាបបង្គំទូលដល់ព្រះមហាក្សត្រ · តាមដំណើរសេចក្តីនោះសព្វគ្រប់ ៗ

ទើបព្រះអង្គមានព្រះបន្ទូលថា កុំអាលឲ្យគាប់វាឡើយ ហើយត្រាស់ឲ្យយកផ្លែល្ពៅអំពីចៅនោះ ទៅដាក់ផ្ទាប់ទល់នឹងទងដែលល្ពៅជ្រុះ

ចេញទៅនោះ តើត្រូវឬមិនត្រូវ រួចសឹមទំលាក់ផ្លែល្ពៅនោះទៅដី ហើយពិចារណារកដើមហេតុឲ្យឃើញពិតប្រាកដសិនសឹមធ្វើទោសវា ។

អាមាត្យទទួលព្រះរាជឱង្ការ ហើយយកផ្លែល្ពៅនោះទៅដាក់ជាប់នឹងទងល្ពៅ តែមិនត្រូវទំនងគ្នាសោះ ហើយទំលាក់ទៅដី ផ្លែល្ពៅនោះក៏ជ្រុះទៅក្នុងថុកកប់កក់ទៅ ទើបព្រះអង្គត្រាស់បង្គាប់ឲ្យគេកាយកក់រកផ្លែល្ពៅនោះ ក៏បានឃើញផ្លែល្ពៅដែលទើបនឹងធ្លាក់ទៅ នឹងផ្លែល្ពៅដែលជុំជ្រុះអំ-ពីមុននោះ ទើបព្រះអង្គឲ្យយកផ្លែល្ពៅដែលជ្រុះអំពីមុននោះទៅដាក់ផ្គាប់លមើល ក៏ឃើញត្រូវនឹងទងនោះមែន ទើបព្រះអង្គត្រាស់បង្គាប់ឲ្យយកផ្លែល្ពៅខុសនឹងទងវាឲ្យទៅបុរសលក់ទំពាក់វិញ ហើយឲ្យលើកលែងទៅ ។ ទើបចៅនោះយកទំពាក់នឹងផ្លែល្ពៅ ទៅកាន់លំនៅអាត្មាវិញ ព្រះមហាក្សត្រទ្រង់រកសេចក្ដីពិតឲ្យបានឃើញជាក់ស្ដែងដូច្នេះ ជាការត្រឹមត្រូវ តាមទំនងនៃខ្លួនធម៌ប្រែពេកហោង ។

ចប់រឿងអាមាត្យរក្សាល្ពៅព្រះរាជទ្រព្យតែប៉ុណ្ណោះ ។